# បច្ចេកទេស
## ជ្រលក់ពណ៌ធម្មជាតិ និងគម្រូផលិតកម្ម តម្បាញសូត្រប្រពៃណីខ្មែរ

# TECHNIQUE
*of Natural Dyeing and Traditional Pattern of Silk Production in Cambodia.*








United Nations
Educational, Scientific and
Cultural Organization

Organisation
des Nations Unies
pour l' éducation,
la science et la culture

PHNOM PENH Office

The Buddhist Institute

# បច្ចេកទេសថ្លៃលក់

## ពណ៌ធម្មជាតិ និងគម្រូផលិតកម្មតម្បាញសូត្រប្រពៃណីខ្មែរ


*រៀបរៀងដោយ*

*លោក ស សុខនី*

*ក. ផាត់ ចន្ទមុនីរដ្ឋា លោក សោម វណ្ណៈ*

*Prepared by Mr. Sor Sokny*

*Miss. Phat Chanmony Ratha, Mr. Som Vannak*



*© រក្សាសិទ្ធិគ្រប់យ៉ាង All Rights Reserved*



*December 2007*



# មាតិកាអត្ថបទ


Foreword by UNESCO . . . . . . 6

យោបល់លោកនាយកវិទ្យាស្ថាន . . . . . . 7

## សេចក្តីផ្តើម

*Introduction* . . . . . . 9

## ផ្នែកទី ១

១. ពណ៌ក្រហម — 1. *Red color* . . . . . . 15

២. ពណ៌លឿង — 2. *Yellow color* . . . . . . 21

៣. ពណ៌ខៀវ — 3. *Blue color* . . . . . . 26

៤. ពណ៌ខ្មៅ — 4. *Black color* . . . . . . 30

## ផ្នែកទី ២

៥. ហូល — 5. *Hol* . . . . . . 37

៦. ផាមួង — 6. *Phamuong* . . . . . . 42

៧. ចរបាប់ — 7. *Chorabab* . . . . . . 46

៨. សារុង — 8. *Sarong Sotr* . . . . . . 48

៩. ក្រមាសូត្រ — 9. *Scarf* . . . . . . 50

១០. ពិដាន និងរនាំង — 10. *Pidan and Roneang* . . . . . . 52

**បញ្ជីរុក្ខជាតិ** *List of plants* ........................ 55

**សទ្ទានុក្រមតម្បាញ** *Technical terms* ...................... 69

**ផែនទី** *Map* ............................... 90

- ប្រទេសកម្ពុជា *Cambodia*
- ខេត្តតាកែវ *Takeo*
- ខេត្តកណ្ដាល *Kandal*
- ខេត្តព្រៃវែង *Prey Veng*
- ខេត្តកំពង់ចាម *Kampong Cham*

**បញ្ជីឈ្មោះអ្នកដែលបានផ្ដល់សម្ភាសន៍** *List of interviewees* ...... 94

**ឯកសារយោង** *References* ........................... 98



# FOREWORD

UNESCO is much honored to have contributed to the successful publication of this book about one of the most important traditional crafts in Cambodia; natural dyeing. The completion of this publication bears testimony to the continuous and intensive efforts of the Buddhist Institute to compile a very useful document on the techniques of natural dyeing so that the future generations of Cambodia may use these traditional techniques as a subsidiary occupation to improve their living conditions and to preserve their cultural heritage.

Natural dyeing in Cambodia incorporates specific techniques to produce colors from natural materials without using chemicals. All the elements involved in this process are available in the country. Of course, this natural color is suitable for the Khmer silk as its vivacity and intensity last for a very long period of time. The secret to this traditional craft is revealed in this precious book. Preserving natural dyeing is essential since this valuable tradition is already disappearing in some areas where craftsmen now tend to rely on chemical colors of doubtful quality.

UNESCO would also like to encourage national institutions to take new measures aiming at safeguarding this promising traditional craft by disseminating knowledge on a much larger scale. Training young Cambodian people with traditional craft techniques is the only way forward to contribute to its preservation. In this respect, UNESCO is ready to provide continuing assistance to the Royal Government for the benefits of the future generations of Cambodia.

**Teruo Jinnai**

UNESCO Representative in Cambodia

# យោបល់របស់នាយកវិទ្យាស្ថាន
## ពុទ្ធសាសនបណ្ឌិត្យ

វិទ្យាសាស្ត្រកាន់តែរីកចម្រើនពីមួយឆ្នាំ ទៅមួយឆ្នាំ សម្ភារៈប្រើប្រាស់គ្រប់បែបយ៉ាងកាន់តែវិវត្តន៍ទៅរកភាពថ្មី និងទាន់សម័យ រួមផ្សំនិងទីផ្សារសេរីមានការប្រកួតប្រជែងឥតឈប់ឈរ សូម្បីតែវប្បធម៌ប្រពៃណី នៃប្រទេសនីមួយៗ ក៏មានការផ្សព្វផ្សាយ ឲ្យប្រទេសផ្សេងៗ ទទួលស្គាល់រៀងៗខ្លួនដែរ ។ ទន្ទឹមនឹងការរីកចម្រើនទាំងអស់នេះយើង ជាកូនខ្មែរក៏ត្រូវតែរក្សា និងផ្សព្វផ្សាយអ្វីដែលជាវប្បធម៌ ប្រពៃណីនៃជាតិយើង ទោះបី មានអ្វីដែលថ្មីនិងទំនើបជាង ក៏យើងមិនភ្លេចនូវអ្វីដែលជាឫសគល់ពិតប្រាកដរបស់យើង ដូចជាការត្បាញ ក្រមា សារុងសូត្រ ហូល ផាមួង ចរបាប់ ពិដាន ដែលមាន លក្ខណៈ ប្រពៃណីជាតិយើង ។ សាកលភាវូបនីយកម្មប្រៀបបានដូចជាកន្ត្រកមួយដែលដាក់ផ្កាចម្រុះពណ៌ ដែលពណ៌ទាំងនោះដំណាងឲ្យវប្បធម៌របស់ជនជាតិនីមួយៗ នៅលើពិភពលោកយើងនេះ ។

គួរកត់សម្គាល់ថា ផលិតផលសូត្រខ្មែរជាច្រើនឥឡូវមិនសូវជ្រលក់ពណ៌ធម្មជាតិទេ ច្រើនតែប្រើល័ខគីមី ដែលជាផលិតផលសម្រេចនាំចូលពីបរទេស ។ ដូច្នេះការប្រើប្រាស់ល័ខធម្មជាតិរបស់ខ្មែរ ពិតជាមិនសូវសម្បូរ ណាមួយល័ខគីមីមានគ្រប់ពណ៌ តែល័ខធម្មជាតិមិនសម្បូរពណ៌ដូចល័ខគីមីទេ ។ ទោះបីជាផលិតផលតម្បាញសិល្បៈសិប្បកម្មទាំងនេះ មានការពិបាកក្នុងការផលិតយ៉ាងណាក៏ដោយ ហើយជាពិសេសទៅទៀតក្នុងការប្រើប្រាស់ល័ខធម្មជាតិនោះរឹតតែពិបាក និងត្រូវការភាពអំណត់ ប៉ុន្តែអ្វីដែលប្រជាជាតិយើងបានទទួលនោះ មិនមែនត្រឹមតែតម្លៃ ក្នុងការទិញលក់សំពត់មួយក្បិននោះទេ គឺថែមទាំងទទួលនូវតម្លៃ និងកិត្តិយសរបស់ជាតិយើងទៀតផង ។

ដោយមើលឃើញដូច្នេះហើយ ព្រមទាំងមានការឧបត្ថម្ភពីអង្គការ UNESCO ផ្នែកថវិកាផងនោះ ក្រុមស្រាវជ្រាវរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានចុះធ្វើការស្រាវជ្រាវ ពីវិធីជ្រលក់ពណ៌ធម្មជាតិ និងគំរូតម្បាញសូត្រប្រពៃណីខ្មែរ នៅក្នុងខេត្តបីមានៈ ខេត្តព្រៃវែង ខេត្តកណ្ដាល និង ខេត្តតាកែវ ដើម្បីទុកជាឯកសារស្រាវជ្រាវតទៅមុខទៀត និងសម្រាប់អ្នកមិនទាន់ចេះឲ្យបានយល់នូវបញ្ហាមួយចំនួនស្ដីពីការផលិតនេះ ។

នៅក្នុងសៀវភៅនេះ លោកអ្នកនឹងស្គាល់នូវក្បាច់ហូល ផាមួង ចរបាប់ សារុងសូត្រ ក្រមាសូត្រ និងពិដានមួយចំនួន ក៏ដូចជាវិធីសាស្ត្រក្នុងការជ្រលក់ពណ៌ធម្មជាតិ ។

ថ្ងៃច័ន្ទ ទី ១០ ខែ កញ្ញា ឆ្នាំ ២០១៣
នាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

The Buddhist Institute

# សេចក្តីផ្តើម

ប្រទេសខ្មែរជាប្រទេសមួយដែលមានវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ដ៏ខ្ពង់ខ្ពស់មួយនៅអាស៊ីអាគ្នេយ៍ អស់កាលដ៏យូរណាស់មកហើយ ។ យ៉ាងណាមិញ តម្បាញគឺជាស្នាដៃសិល្បៈ សិប្បកម្មខ្មែរមួយ ដែលមានតាំងពីក្រោយសម័យហ្វូណន ប៉ុន្តែមានអ្នកស្រាវជ្រាវខ្លះបាននិយាយថា ខ្មែរចេះផលិតសូត្រតាំងពីមុនសម័យប្រវត្តិសាស្ត្រទៅទៀត ។ ប្រជាជាតិខ្មែរចេះត្បាញសូត្រជាច្រើនប្រភេទមានក្បាច់រចនាផ្សេងៗពីគ្នាដូចជា ល្បើក ព្រៃលាត អន្លូញ ក្រមា សារុងសូត្រ ចរបាប់ ស៊ឹង ហូល ផាមួង ពិដាន ប្រកបដោយពណ៌ល្អស្រស់ដែលចម្រាញ់ចេញពីរុក្ខជាតិជាច្រើនមុខ និងធាតុផ្សំជាច្រើនទៀត ។ ទាំងអស់នេះគឺសម្រាប់ប្រើប្រាស់ក្នុងការបិទបាំងរាងកាយ និងជាគ្រឿងលម្អផ្សេងៗដែលប្រកបទៅដោយពណ៌ធម្មជាតិគួរជាទីគយគន់ តាំងពីយូរយារណាស់មកហើយរហូតដល់សម័យសព្វថ្ងៃនេះ ក៏នៅតែមិនសាបសូន្យដែរ ។ យើងឃើញថា តម្បាញសូត្រខ្មែរមានច្រើនប្រភេទមានក្បាច់រចនាផ្សេងៗគ្នា ហើយស្នាដៃសិល្បៈនេះបានបន្សល់ទុកជាភស្តុតាងតាមរយៈរូបចម្លាក់អប្សរាដែលស្លៀកសំពត់ប្រកបដោយក្បាច់រចនាយ៉ាងល្អវិចិត្រ នៅលើជញ្ជាំងប្រាសាទអង្គរវត្ត និងប្រាង្គប្រាសាទជាច្រើនទៀតនៅលើទឹកដីកម្ពុជាដ៏ពិសិដ្ឋយើងនេះ ។

សម្លៀកបំពាក់ប្រពៃណី ដែលធ្វើអំពីសូត្រដូចជា ហូល ផាមួង ចរបាប់ សារុងសូត្រ ។ល ។ ជាសម្លៀកបំពាក់ប្រពៃណីខ្មែរតាំងពីបុរាណមក មិនថារាស្ត្រ នាម៉ឺន មន្ត្រី តូច ធំ ព្រះមហាក្សត្រ សុទ្ធតែប្រើសម្លៀកបំពាក់ដែលធ្វើពីស្នាដៃហត្ថពលកម្មទាំងនេះ ។ ទោះជាសម័យបច្ចុប្បន្នមានសម្លៀកបំពាក់ទំនើបៗនាំចូលពីបរទេស ឬ ផលិតក្នុងស្រុកក៏ដោយ ក៏ក្នុងពិធីរៀបមង្គលការ និងពិធីបុណ្យប្រពៃណីជាតិនានា រួមទាំងពិធីបុណ្យផ្សេងៗនៅក្នុងព្រះបរមរាជវាំង ហូល ផាមួង ចរបាប់



នៅតែជាសម្លៀកបំពាក់ពេញនិយមរបស់ប្រជាជនខ្មែរដដែល ។ តើសិប្បកម្មតម្បាញសូត្រ នឹងការជ្រលក់ពណ៌ធម្មជាតិមានដំណើរការផលិតយ៉ាងដូចម្តេចខ្លះ? ពិតមែនហើយការត្បាញ ហូល ផាមួង សារុងសូត្រ ចរបាប់ ពិតជាមានការពិបាកណាស់ ទម្រាំបានសូត្រមួយសំពត់ ឬមួយក្បិនយកមកស្លៀកពាក់ ឬគុបតែងជាគ្រឿងលម្អផ្សេងៗ នៅតាមទីកន្លែងផ្សេងៗដែលរៀបចំជាលក្ខណៈខ្មែរ ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍មកពីប្រទេសផ្សេងៗនោះ សិប្បករយើងត្រូវចំណាយមិនត្រឹមតែប្រាក់ដើម្បីទិញសូត្រនោះទេ គឺថែមទាំងទឹកចិត្ត និងទេពកោសល្យរបស់ខ្លួនទៀតផង ។ ប៉ុន្តែទោះជាមានការលំបាកយ៉ាងណាក៏ដោយ ក៏ពួកគាត់នៅតែព្យាយាមធ្វើការយ៉ាងផ្ចិតផ្ចង់ដើម្បីត្បាញផលិតផលទាំងអស់នេះ ។

យើងសង្ឃឹមជឿជាក់ថា លទ្ធផលនៃការសិក្សាស្រាវជ្រាវពីវិធីជ្រលក់ពណ៌ធម្មជាតិនេះ វាមានសារៈប្រយោជន៍បំផុតក្នុងការជួយបង្ហាញគម្រូតម្បាញបុរាណរបស់សិប្បករយើង ក្នុងការត្បាញសូត្រ និងការជ្រលក់ពណ៌ធម្មជាតិដល់បងប្អូនប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសដែលមានបំណងចង់ប្រកបអាជីវកម្មធ្វើសូត្រខ្មែរជាមួយនិងពណ៌ធម្មជាតិ ។ វាមិនមែនគ្រាន់តែអាចជួយដល់អាជីវកម្មធ្វើតម្បាញសូត្រ និងការជ្រលក់ពណ៌បែបធម្មជាតិតែប៉ុណ្ណោះនោះទេ ប៉ុន្តែវាថែមទាំងជាឯកសារមួយ ដែលអាចជួយរក្សាទ្រទ្រង់ប្រពៃណីទំនៀមទម្លាប់ក្នុងការរស់នៅរបស់ប្រជារាស្ត្រខ្មែរជំនាន់ក្រោយៗទៅទៀត ។

# INTRODUCTION

Cambodia is a country in Southeast Asia with a long history of great culture and tradition. Weaving is a Khmer craft that has existed since the Funan period. However, some researchers have said that the Khmer could produce silk even in the prehistoric period. Khmer people could weave many kinds of silk products with different decorative patterns, such as *lboek prealeat*, *angloung* (checkered cloth), *krama* (scarf), *sarong sotr, chorabab, soeung, hol, phamuong, pidan* (used in Buddhist ceremonies) in magnificent colors, which were extracted from trees and other materials. [For a long time] people have been using these types of materials for clothes and in decorations because of their glorious natural colors. This craft [weaving] is clearly apparent on the artistic skirts of the Apsara on the walls of Angkor Wat and other temples in the wonderful territory of the Kingdom of Cambodia.

Clothes made from silk include *hol, phamuong, chorabab*, and *sarong sotr,* these traditional Khmer clothes have long been used by ordinary people, low and high-ranking officials and the king. Although today there are many modern clothes imported from foreign countries or produced locally, *hol, phamuong*, and *chorabab* are still popular in wedding ceremonies, traditional festivals and royal ceremonies.

What are the processes of weaving and natural dyeing? In fact, it is a very hard work to weave *hol, phamuong, sarong sotr, chorabab* to produce one skirt or one *kbin* for clothing or Khmer-style decorations for places organized to attract foreign tourists. It costs craftsmen not only money to buy the silk but also mental effort and talent. However hard it is, they work on it with diligence.

We believe that the result of research on natural dyeing is vital proof to show different patterns of silk weaving and natural dyeing to all Khmer people who wish to operate businesses in Khmer silk products made from natural colors. It not only supports silk craftwork and natural dyeing but also serves as a document to preserve Khmer traditions and customs for the next generation.



# ផ្នែកទី ១

# *Part 1*

# ពណ៌ក្រហម



នេះជារូបលោកតា ជា ឈន អាយុ ៨០ឆ្នាំ
*Ta Chea Chhorn, 80 years old*

យោងតាមការសម្ភាសន៍ជាមួយអ្នកផលិត យើងបានរកឃើញថា ពណ៌ក្រហមត្រូវបានផលិតចេញពី "ល័ខក្រម៉" ។ សព្វថ្ងៃនេះ នៅក្នុងប្រទេសកម្ពុជា ដំណើការនៃការផលិតល័ខក្រម៉ ស្ទើរតែអស់ទៅហើយ លើកលែងតែក្នុងខេត្តក្រចេះ នេះបើតាមសម្ដីលោកតា **ជា ឈន** អាយុ ៨០ ឆ្នាំ រស់នៅក្នុងភូមិ ត្រពាំងចំបក់ ឃុំសម្រោសពេន ស្រុកសំរោង ខេត្តតាកែវ ។ គាត់បានផលិតល័ខក្រម៉ជាង ៦០ ឆ្នាំហើយ ទោះបីជាក្នុងរបប ប៉ុល ពត ក៏ដោយ ។ គាត់ទើបតែឈប់ផលិតក្នុងឆ្នាំ ២០០៥ ពីព្រោះសុខភាព និងការបាត់បង់ដើមឈើអស់ជាច្រើនក្នុងតំបន់ដែលគាត់រស់នៅ ។ ដើមឈើដែលផ្ដល់ទិន្នផលល័ខខ្ពស់ គឺដើមត្រាង, ដើមសង្កែ, ដើមកកោះ, ដើមច័ន្ទគិរីជាដើម ។ ល័ខក្រម៉ភាគច្រើនដែលប្រជាជនប្រើសព្វថ្ងៃ គឺនាំចូលមកពីប្រទេសឡាវប្រមាណ ១០ តោន ក្នុង ១ ឆ្នាំ ។

ដើម្បីទទួលបានពណ៌ក្រហម យើងត្រូវបំបែកល័ខជាដុំតូចៗ ហើយយើងរម្ងាស់រយៈពេល ២ ម៉ោង បន្ទាប់មកយើងច្រោះ និងរក្សាទុកតែទឹកពណ៌ក្រហម សម្រាប់លាយជាមួយទឹកស្ងឹកអំពិល ដែលយើងបានរម្ងាស់ជាស្រេច ឧទាហរណ៍ ប្រសិនបើយើងផលិតហូលមួយក្បិន (បណ្ដោយ ៤ ម៉ែត្រ ទទឹង ១ ម៉ែត្រ) យើងត្រូវការល័ខក្រម៉ ១ គីឡូក្រាម (ប្រសិនបើសើម) និងស្ងឹកអំពិល ១ គីឡូក្រាម ។ ការជ្រលក់ពណ៌នេះ យើងត្រូវការវត្ថុធាតុដើមនីមួយៗដែលអាចផលិតសារធាតុរាវចំនួន ២ លីត្រ ក្នុងមួយមុខៗ ។ គួរកត់សម្គាល់ថាជាធម្មតា ទឹកម្ជូរដែលផលិតមកពីស្ងឹកអម្ពិលមានគុណភាពល្អជាងផ្លែ ។

# Red Color

Through the interview with the [dye] producers, we learned that the color red was made from a red dye called *“leak sramor”*. According to Grandfather Chea Chhorn, aged 80, living in Trapeang Cambok village, Samreahpen commune, Samrong district, Takeo province, in Cambodia, the production of red dye is currently on the verge of extinction, except in Kratie province. He had produced red dye for more than 60 years, even during the Pol Pot regime. He just stopped producing it in 2005 because of health problems and the decrease of trees around his area. Trees that give high color output are *trang* (Ficus altissima Blume), *sangke* (Combretam quadrangulare Kurz), *kakoh* (Sindora Siamensis Teijsmex), chankiri (Albizia Saman)…etc. Most red dye used today, approximately 10 tonnes per year, is imported from Laos.

To get color for red dye, we need to break it into small pieces then decoct it for two hours. After that we decant it and retain only the red liquid and mix it with water from decocted tamarind leaves. For example, if we are producing *hol* for one *kbin* (4 meters long and 1 meter width) we need one or one and a half kilograms of red dye (if it is wet) and one kilogram of tamarind leaves. These materials will produce two liters of liquid dye each. It should be noted that traditionally sour liquid abstracted from tamarind leaves is of better quality than that of the liquid abstracted from tamarind fruits.



*នេះជាដើមត្រាង ដែលដុះនៅក្នុងខេត្តតាកែវ ។ កូនសត្វល័ក្កដែលបង្កើតជាល័ខក្រមួ ចូលចិត្តរស់នៅលើដើមនេះ ដែលធ្វើឲ្យវាអាចផលិតល័ខបានទិន្នផលខ្ពស់ ។ សព្វថ្ងៃមិនសូវមានឃើញដុះច្រើនទេ ក្នុងរយៈពេលដែលក្រុមស្រាវជ្រាវបានចុះទៅអង្កេត ។*

*This is Trang tree in Takeo province. It can produce red dye in high percentage. There are not many in the fieldwork observation.*



*នេះជាដើមសង្កែ ដែលមានដុះច្រើននៅតាមតំបន់ជនបទ ។*

*Sangke Tree which are frequently seen in rural area*



*ល័ខក្រមួ៏ដែលគេដាក់ក្នុងបាវ*

*Red dye kept in sack*



*ដើមអម្ពិល (ស្លឹក និងផ្លែ)*

*Tamarind tree (leaves and fruits)*



*ស្លឹកអម្ពិលដែលបានស្ងោរ*

*Boiled Tamarind leaves*

សូត្រសើមត្រូវបានជ្រលក់ពណ៌ក្រហមដោយបោក និងស្ងោរក្នុងទឹកនោះ ចំនួន ១០ នាទី ។ យើងត្រូវតែបោកវាយ៉ាងតិចណាស់ប្រាំបីដំណាក់កាលដើម្បីឲ្យពណ៌ចូលគ្រប់សរសៃសូត្រ ។ មួយដំណាក់កាលស្មើនឹង ១២០ ដង ។

នៅក្នុងដំណាក់កាលនេះពណ៌យើងទទួលបានក្រហមស្រាល ឬពណ៌ផ្កាឈូក ។ ពណ៌ក្រហមនឹងលេចឡើងកាន់តែច្បាស់បន្ទាប់ពីយើងបានជ្រលក់ពណ៌លឿង ។

Wet silk was dyed in red liquid by beating and boiling it in the liquid for ten minutes. We have to beat it at least eight times to allow each thread of the silk to absorb the color. Each stage equals one hundred and twenty beats.

At this stage, the color we get is light red or pink. The red color will show clearly after we put it in a yellow-colored dye.



*ទឹកល័ខក្រម៉*

*Red dye liquid*



*ការប្រោះយកតែទឹកល័ខ*

*Decanting the red dye liquid*



ការជ្រលក់ពណ៌គាធ(សូត្រ)

*Dyeing silk*



ការធ្វើឲ្យពណ៌ក្រហមជ្រាបចូលទៅគ្រប់សរសៃសូត្រ

*Beating allows each thread of the silk to absord the red color.*



ការស្ងោរគាធធ្វើឲ្យពណ៌កាន់តែជ្រាបសព្វល្អ

*Boiling silk*

# ពណ៌ក្រហម Red Color



# ពណ៌លឿង

ដើមឈើឈ្មោះថាព្រហូត ជាវត្ថុធាតុដើមដ៏សំខាន់ដើម្បីបង្កើតពណ៌លឿង ។ ដើមនោះអាចរកបាននៅតាមតំបន់ខ្ពង់រាបប្រទេសកម្ពុជា ។ គេចិញ្ច្រាំសម្បកវាជាដុំតូចៗ និងរម្ងាស់ប្រមាណកន្លះម៉ោង ។ បន្ទាប់មកយើងច្រោះវាយកតែទឹកពណ៌លឿង លាយជាមួយម្សៅសាជូរចំនួនមួយរយក្រាម ដែលនាំឲ្យទឹកនោះវានឹងបង្ហាញពណ៌លឿងស្រាល ។

ទឹកក្បួងត្រូវបានផលិតពីផេះសំបកផ្លែចេក គឺមានគុណភាពល្អប្រសើរជាងផេះដើមសង្កែ ឬក៏ដើមឈើផ្សេងទៀត ។ ផេះសម្បកចេក ១ គីឡូក្រាម អាចផលិតទឹកក្បួងបាន ៦ លីត្រ (ច្រោះរួចរាល់) ។ នៅក្នុងចំណុះនេះ យើងចែកជាបីផ្នែក ហើយពីរផ្នែក ត្រូវបានរក្សាទុកសម្រាប់ការលាងសូត្រ ឬឯផ្នែកដែលនៅសល់ទុកសម្រាប់ត្រាំគ្រាប់ជម្ពូ ។

ទឹកក្បួងអាចផលិតពីរុក្ខជាតិជាច្រើនដូចជា ផ្ទីបន្លា សម្បកផ្លែគ ឬ រុក្ខជាតិធម្មតា តែមិនសូវមានគុណភាពល្អ ។

ប្រសិនបើយើងចង់ទទួលពណ៌លឿងចាស់ យើងត្រូវការបន្ថែមពណ៌ពីគ្រាប់ជម្ពូដែលអាចរកទិញបានក្នុងទីផ្សារ ហើយយើងប្រើប្រាស់វាចំនួន ១៥០ ក្រាម សម្រាប់ហូល ១ ក្បិន ។

# Yellow Color

A tree named *prahout* (Gareinia Vilersiana Pierre) is the main raw material to produce a yellow color. This tree can be found in the highlands of Cambodia. Its bark is chopped into small pieces and decocted for half an hour. Then we decant only the yellow liquid and mix it with powdered alum (100 grams), which converts the liquid to a light yellow.

Potash water was produced from banana skin ash, which is better than from *sangke* tree ash or from other plants. One kilogram of banana ash can produce six liters of potash water (after decanting). We divide this volume into three parts and two of them are kept for washing silk and the rest for soaking with annatto grain.

Potash water can be produced from *phti* (Amaranthus spinosus L.) or other plants, but it is of low quality.



*សម្បកព្រហូតក្រៀម*

*The dried bark of Prahout tree*



នេះជាស្លឹក ផ្លែ និងមែកព្រហូត
*Leaves, fruits and branches of Prahout*



ការបំបែកដុំល័ខក្រហម និងចិញ្ច្រាំសម្បកព្រហូតដើម្បីដាក់ស្ងោរ
*Breaking red dye and chopping bark of Prahout*



ការស្ងោរសម្បកព្រហូត
*Boiling bark of Prahout*



ទឹកព្រហូតក្រោយពេលលាយជាមួយម្សៅសាជូរ
*Prahout liquid after mixed with aluminum powder*



ការលាងគាធជាមួយទឹកក្បុង
*Washing silk with potash water*

យើងខ្ចប់គ្រាប់នេះទៅក្នុងកន្សែងរួចយកទៅត្រាំ ហើយ និងដុសវាទៅក្នុងទឹកក្បុង ២ លីត្រ បន្ទាប់មកយើងបោកសូត្រតាមធម្មតា ។ ក្រោយមកទៀត យើងស្ងោរសូត្រ ជាមួយទឹកព្រហូត ១៥ នាទីនោះសូត្រនឹងមានពណ៌លឿងចាស់ជាពុំខាន ។

If we want to get a dark yellow color, we need to add color from annatto grains (Bixa orellana), which can be bought in markets. We use one hundred and fifty grams for one *kbin* of *hol*. We pack the grains in the scarf, soak and rub them in the remaining two liters of potash water. Then we beat the silk as normal. After that we boil the silk with *prahout* water for fifteen minutes. The silk will become a dark yellow.



ដើមជម្ពូ
*Annatto tree*



គ្រាប់ជម្ពូ
*Annatto grains*



ការត្រាំគ្រាប់ជម្ពូក្នុងទឹកក្បុង
*Annatto grain in potash water*



ការជ្រលក់គាធក្នុងទឹកក្បុងពណ៌លឿង
*Dyeing silk in yellow potash water*



ការស្ងោរសូត្រក្នុងទឹកព្រហូត
*Boiling silk in Prahout liquid*

# ពណ៌លឿង Yellow Color





# ពណ៌ខៀវ

សព្វថ្ងៃនេះការផលិតពណ៌ខៀវ គឺជាការពិបាកមួយជាងពណ៌ផ្សេងទៀត ពីព្រោះបន្ទាប់ពីរបប ប៉ុល ពត មនុស្សដែលដឹងពីរបៀបផលិតស្លាប់ស្ទើរតែអស់ទៅហើយ ។ ករណីផ្សេងទៀតមកពីឥទ្ធិពលនៃសាកលភាវូបនីយកម្មជារួមដែលមានន័យថាពណ៌ខៀវដែលផលិតពីធាតុគីមីងាយស្រួលស្វែងរកក្នុងទីផ្សារ ហើយថោកជាង ។ ដូច្នេះការប្រើផលិតផលសូត្រ ឬអំបោះពណ៌ខៀវពីពណ៌ធម្មជាតិមានការថយចុះយ៉ាងលឿន ហើយស្ទើរតែផុតរលត់អស់ទៅហើយ ។ តាមរយៈវិធីសាស្ត្រចាស់ យើងគ្រាន់តែអាចធ្វើបានពណ៌ស្រដៀងតែប៉ុណ្ណោះ ។

ជាប្រពៃណីយើងប្រើប្រាស់ដើមត្រំ ដែលអាចរកបាននៅក្នុងភូមិ ឬក៏ដាំវា ។ យើងអាចប្រើប្រាស់ស្លឹកត្រំ ដោយបុកវា ហើយពូតយកទឹកពណ៌បៃតង ឬត្រាំស្លឹកត្រំស្រស់ពីរយប់ បន្ទាប់មកជ្រលក់នឹងសូត្រ ។ គុណភាពផលិតតាមវិធីនេះមិនសូវល្អ ពីព្រោះពណ៌នឹងហើរនៅក្នុងពេលខ្លីខាងមុខ ។

ដូច្នេះ យើងត្រូវការផលិតធ្លះ ។ យើងត្រាំដើមត្រំក្នុងទឹក១យប់ បន្ទាប់មកយើងយកដើមត្រំចេញ ទុកតែកាកសំណល់ និងទឹកដែលមានក្លិនអាក្រក់ ។ យើងបន្ថែមកំបោររលៀស និងស្ករត្នោតជារៀងរាល់ថ្ងៃរយៈពេល ១ អាទិត្យ ឬយូរជាងនេះ ។ សារធាតុរាវនេះគេហៅថាធ្លះ ដែលគេអាចជ្រលក់ពណ៌សូត្រ ឬអំបោះបាន ។ កាលពីមុនក្នុងដំបន់ ឬភូមិមួយ គ្រួសារនីមួយៗមានជំនាញរៀងៗខ្លួន ។ គ្រួសារខ្លះអាចជាអ្នកត្បាញ ជាជាងឈើ និងអ្នកផ្សេងទៀត អាចជាអ្នកជ្រលក់ពណ៌ ។ ដំណើរការផលិតធ្លះនេះ ពីមុនយ៉ាងហោចណាស់ក៏ប្រើរយៈពេល ១ សប្តាហ៍ ដើម្បីធ្វើឲ្យរួចរាល់ ។



# Blue Color

Today producing blue color is harder than other colors because since the Pol Pot regime, most of the people who knew how to produce it have died. Other causes are the impact of globalization, which means the blue color is made from chemical substances, which are easy to find in the market and cheaper. Therefore, the use of natural blue color for silk or cotton clothes is decreasing rapidly and almost becoming extinct. It is only through the old methods that we can make a similar color.

Traditionally we use *trom* tree (Indigofera tinetoria), which can be found in the villages or by planting it. We can use *trom's* leaves by pounding and wringing out the green liquid or soaking the fresh leaves for two nights then dyeing the silk. The quality of this color is not good because the color will quickly fade.

So, we need to produce *dhlah*. We soak the *trom* tree for one night then take the tree and keep only the residue and the bad smelling water. Then we add shell limestone and palm sugar every day for one week. This liquid is called *dhlah* and can be used to dye silk or cotton. In the past, in one region or village, each family had its own specialties. The family could have the weaver, the carpenter and the dyer. The previous production method takes at least one week to complete.



*ដើមត្រំ*

*Trom tree*



*ស្លឹក ផ្លែ និងគ្រាប់ត្រំ*

*Leaves, fruits and grains of Trom tree*

ក្នុងករណីត្រូវការប្រញាប់ពួកគេត្រូវតែផលិត មរ ដែលជាផ្នែកមួយនៃធ្លះខាប់ ឬជាធម្មតា យើងហៅថាមេធ្លះ ។ សារធាតុខាប់នេះ អាចរក្សាបានយូរដើម្បីលាយជាមួយធ្លះថ្មី និងអាចជ្រលក់ពណ៌បានឆាប់ ។

Hence, in urgent cases, they have to produce *mor*, which is a part of thick *dhlah*. This thick liquid can be kept for a long time to mix with new *dhlah* and is a quick material for dyeing.



*មរ នៅក្នុងខេត្តតាកែវ*

*Mor in Takeo province*



*ធ្លះនៅផ្ទះលោក សួង មិច ក្នុងខេត្តតាកែវ*

*Dhlah at Mr. Suong Mich's house*



# ពណ៌ខៀវ Blue Color



ដើមត្រំ
*Trom tree*

១ ត្រាំ ២យប់
*Soak two nights*



\+

កំបោរលាស
*Shell lime stone*



២ ពាងផ្លះ
*Jar to keep Dhlah*



៣ ពាងដាក់ មរ
*Mor*



\+

កំបោរលាស
*Shell lime stone*

# ពណ៌ខ្មៅ

ពណ៌នេះ គឺត្រូវបានគេចំរាញ់យកចេញពីសម្បកដើមអំពិលទឹក និងដើមឆ័ត្រ ។ យើងបកយកសម្បកដើមឈើទាំងពីរនេះ ២ គីឡូក្រាម នៃដើមឈើនីមួយៗ បន្ទាប់មកយើងស្ងោរវា ២ ម៉ោង ។ យើងច្រោះយកតែទឹក និងរក្សាសីតុណ្ហភាពរបស់វានៅធម្មតា បន្ទាប់មកយើងអាចជ្រលក់សូត្រ ហើយស្ងោរសូត្រម្តងទៀតជាមួយទឹកនេះ ។ ក្រោយមកយើងបោកសូត្រជាមួយទឹកស្អិន ហើយហាលសម្ងួតវានៅក្នុងម្លប់ និងខ្យល់ យើងអាចទទួលបានសូត្រពណ៌ខ្មៅសម្រាប់ត្បាញ ។

ទឹកស្អិន គឺជាលទ្ធផលនៃប្រតិកម្មរវាងដែកច្រេះ ១ គីឡូក្រាម ស្ករត្នោតមួយគីឡូក្រាម ក្រូចឆ្មារ ៣០ផ្លែ និងទឹក ៣០ លីត្រ ។ សម្រាប់ក្រូចឆ្មារ យើងត្រូវការហាន់ជាចំណិតស្តើងៗ ។ ជារៀងរាល់ថ្ងៃ យើងត្រូវបន្ថែមចំណិតក្រូចឆ្មារជាលំដាប់ដើម្បីទទួលបានគុណភាពល្អប្រសើរនៃទឹកនេះ ។ យើងរក្សាទុកវត្ថុធាតុដើមទាំងនេះនៅក្នុងពាងធំមួយ និងក្រោមពន្លឺព្រះអាទិត្យពីចំនួន ៥ ថ្ងៃ ទៅមួយសប្តាហ៍ ។

ក្នុងករណីខ្លះយើងអាចស្ងោរចំណិតតូចៗ នៃដើមគូលែនជាមួយនឹងដែករយៈពេល ២ ម៉ោង ហើយយើងអាចជ្រលក់សូត្របាន ។ ធ្វើរបៀបនេះយើងថែមទាំងទទួលបានពណ៌ខ្មៅទៀតផង ។

ក្រៅអំពីរុក្ខជាតិដែលបានរៀបរាប់ខាងលើ គឺនៅមានរុក្ខជាតិផ្សេងៗទៀតដែលគេ អាចយកមកចម្រាញ់យកពណ៌បានដូចជាៈ

- ដូង(ស្រកី) ពណ៌ដូចស្រកីដូង
- ខ្នុរ ពណ៌លឿងតិចៗ
- ន់នោង ពណ៌ខៀវខ្ចី
- ពោធិ៍ និងស្តៅ ពណ៌លឿងចាស់ជាដើម ។



# Black Color

This color was extracted from *ampil toek* (Tamarind water tree) and *chatra* tree. We strip two kilograms of the barks from each of the two trees, and then boil them for two hours. We decant only the water and keep it until it lowers to a normal temperature. Next, we can dye the silk. After that, we boil the silk again with this water. Then we wash the silk with *smin* water and dry it in shade and wind, so we can get black silk for weaving.

*Smin* water is the result of a reaction between one kilogram of rusty iron, one kilogram of sugar palm, thirty lemons and thirty liters of water. We need to slice the lemon before using it. Every day we have to add a small piece of a lemon in order to improve the quality of the water. We keep these materials in a big jar and leave them in the sunlight for five days to one week.

In some cases, we can boil sliced litchi tree (Litchi chinensis sonn) with iron for two hours and we can dye the silk. This also gives a black color.

Beside the plants we introduced above, some other plants that people could abstract colors from include:

- Coconut
- Jackfruit
- *Nornong* (Luffa acutan gula -(L.) Roxb.)
- *Po* and *sdaov* (Aglaia- leptantha Miq)



*ដើមអម្ពិលទឹក*

*Ampil toek tree (Tamarind water tree)*





ទឹកស្មុីន

*Smin water*



ពាងធំសម្រាប់ដាក់ទឹកស្មុីន នៅក្រោមកំដៅព្រះអាទិត្យ

*Big jar to keep Smin water under sun light*

ចំណិតដើមគូលេន និងដែកគោល

*Sliced Litchi tree and iron*

# ពណ៌ខ្មៅ Black Color





# ផ្នែកទី ២

# *Part 2*

# ហូល

គាធគឺជាសំណុំសូត្រដែលគេចងសម្រាប់យកទៅជ្រលក់ពណ៌ ដែលភាសាអង់គ្លេស មានន័យថា អ៊ីខាត់ ។ ត្រង់នេះខ្មែរមានលក្ខណៈពិសេសរបស់ខ្លួនមួយ ។ គាធសសុទ្ធ ជាដំបូងគេ ត្រូវជ្រលក់នឹងពណ៌ក្រហម បន្ទាប់មកគេកាត់ចំណងពណ៌ក្រហមនេះ រួចហើយគេជ្រលក់នឹងពណ៌លឿង និងបន្តបន្ទាប់គឺពណ៌ខៀវ ។

ចំណងគាធៈ កាលពីមុនយើងប្រើខ្សែដែលផលិតពីស្រទបចេកជ្វា ដែលពុំទាន់ចេញផ្លែ ។ គេប្រៀកស្រទបចេកនោះ រួចហាលថ្ងៃឲ្យស្រពាប់ទើបអាចចងបាន ។ សព្វថ្ងៃខ្សែដែលធ្វើពីនីឡុងត្រូវបានគេយកមកជំនួស ព្រោះតែកង្វះខាតដើមចេកប្រភេទនេះ ។ ម្យ៉ាងមកពីជំនឿប្រជាជនខ្មែរយើង ដែលហាមមិនឲ្យដាំនៅក្បែរផ្ទះ ។ លើកលែងតែនៅក្នុងអង្គការខ្លះដូចជា វិទ្យាស្ថានវាយនភ័ណ្ឌប្រពៃណីខ្មែរ ដែលមានទីតាំងក្នុងខេត្តសៀមរាបជាដើមគឺនៅប្រើប្រាស់នៅឡើយ ។

ក្នុងប្រពៃណីខ្មែរមានក្បាច់គោមហូលច្រើនណាស់ ដែលកើតឡើងពីគំនិតច្នៃប្រឌិតផ្សេងៗ ពីក្បាច់គោមបុរាណរបស់សិប្បករយើងពីមួយជំនាន់ទៅមួយជំនាន់ ។ តាមការឲ្យដឹងពីអ្នកតម្បាញចាស់ៗ បានឲ្យដឹងថា ក្នុងការធ្វើហូលមួយក្បិន គេត្រូវការរយៈពេលយូរណាស់ គឺយ៉ាងតិចបីខែ ព្រោះពួកគាត់ត្រូវចិញ្ចឹមដង្កូវនាងដើម្បីផលិតសូត្រ ជ្រលក់ពណ៌ និងត្បាញដោយខ្លួនឯង ។ គួរកត់សម្គាល់ថា ក្បាច់គោមហូលពីបុរាណមានលក្ខណៈធំៗ ជាងសព្វថ្ងៃដូចជា ក្បាច់គោមធំ គោមខ្ទឹមច័ន្ទ គោមខ្សែរពីរជាន់ គោមភ្នែកគោជាដើម ។

ការត្បាញហូលទាមទារឲ្យមានការព្យាយាមខ្ពស់ ។ អ្នកត្បាញត្រូវបេះតម្រឹមសរសៃសូត្រដើម្បីឲ្យលេចចេញជារូបគោមត្រង់ និងស្អាតល្អ ។

# Hol

Kiedh is a skein of silk which weavers tie for dyeing, in English called ikat. Khmer weavers have their own special technique to do that. White *kiedh* was first dyed with red, as I explained in Part 1, then with yellow and lastly with blue.

To tie the *kiedh*, we use young banana sheath, but today it has been replaced by nylon. There are some organizations still preserving this technique, for example the Institute for Traditional Khmer Textile located in Siem Reap. According to Khmer superstition, people believe this kind of banana tree cannot be planted near their houses.

There are many patterns of *hol* in Khmer tradition, which were created by weaver from generation to generation. Through the interviews with old weaver, we found that in the past, to produce one *kbin* of *hol*, they had to spend at least three months to complete the work. This takes a long time because they need to feed cocoons to produce silk, dye and weave it by themselves. It should be noted that previous patterns were bigger than those of today, such as *phnek Ko* (cow eyes), *khlim chan*, double lines…etc.

To get a high quality of hol, the weaver needs to have rich experience and diligence, and take great care.



*ការចងគាធដោយខ្សែចេកមុន នឹងយកទៅជ្រលក់ពណ៌*
*Tieing Khiedh before dyeing*



*ការកាត់ចំណងគាធលើកទីមួយដើម្បីជ្រលក់ពណ៌លឿងជាបន្ត*
*Cutting Khiedh tie then dye with yellow color*



*សូត្រដែលគេវៃចូលខ្នាល់រួចបម្រុងនឹងត្បាញ*
*Silk ready for weaving*



*គោមភ្នែកគោមកពីខេត្តតាកែវ*
*Kom (Lantern)  Phnek Ko (cow eyes) from Takeo*



គោមកូនហង់

*Kom Kon Hang*



គោមផ្ការាំង

*Kom Phka Raing*



គោមផ្កាឈូករ័ត្ន

*Kom Phka Chhouk Roat*



គោមផ្កាម្លិះ

*Kom Phka Mlis*



អ្នកតម្បាញសូត្រនៅស្រុកបាទីខេត្តតាកែវ

*Hol weaver in Bati district, Takeo province*



គោមត្បូងពេជ្រជាស្នាដៃរបស់លោក ង៉ែត ម៉េង ខេត្តតាកែវ

*Kom tbong pich, Mr. Nget meng's work, Takeo*



គោមខ្សែអង្រឹង

*Kom Khse Angring*



គោមកូនហ៊ីង

*Kom Kon hing*



គោមចំណិតចាហួយមកពីឃុំព្រែកចង្ក្រាន

*Kom Chamnit Chahuoy from Prek Changkran Commune*

# ផាមួង

ផាប្រភេទមួយនៃសំពត់ខ្មែរយើង ហើយមានច្រើនពណ៌ទៅតាមតម្រូវការ ។ ផាមួងភាគច្រើនគឺមានពណ៌តែមួយ ។ យើងនៅចាំបានថាកាលពីប៉ុន្មានឆ្នាំមុន ផាមួងកទា មានន័យថា ពណ៌ដូចកនៃសត្វទាមានការពេញនិយមខ្លាំងណាស់ក្នុងចំណោមអ្នកប្រើប្រាស់ ។

តាមធម្មតាគេត្បាញផាមួងដោយប្រើថ្នូរចំនួន ៣ យ៉ាងតិច តែអាចច្រើនជាងនេះ ក្នុងករណីដែលផលិតករចង់រចនាបន្ថែមនូវ ជរជើង ផ្កា ឬក្បាច់ផ្សេងៗ ។ នៅកោះដាច់មានត្បាញ រហូតដល់ថ្នូរចំនួន ៣០ ។ ផាមួងនេះគេឲ្យឈ្មោះថា ផាមួងត្បូងពេជ្រ ដែលកំពុងតែមានភាពល្បីល្បាញ ។

# Phamuong

*Phamuong* is a kind of Khmer weaving product that has many colors, as required by users, but generally has only one color per piece. We remember that recently *Phamuong Kor Tea* (the color is similar to the color of a duck's neck) has been very well known.

Weavers use at least three *thkor* or more if that *phamuong* has a pattern or hem decoration. In Koh Dach, weavers use up to 30 *thkor* for the one called *phamuong tbong pich* (diamond *phamuong*), which has now become popular.



*អ្នកតម្បាញហូល និងផាមួងនៅឃុំព្រែកចង្ក្រាន ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង*

*Weaver in Prek Changkran commune, Sithor Kandal district, Prey Veng province*



*ផាមួងជរជើងក្បាច់អង្គរ*
*Hem of Phamuong, Angkor pattern*



*ផាមួងជរជើងក្បាច់បន្ទាយស្រី*
*Hem of Phamuong, Banteay Srey pattern*







ទាំងនេះជាពណ៌ និងក្បាច់ផ្សេងៗនៃផាមួងត្បូងពេជ្រ

*These are different colors and pattern of Phamoung Tbong Pic*





# ចរបាប់

តាមការអង្កេតសព្វថ្ងៃ តំបន់ដែលនៅផលិតចរបាប់នេះគឺនៅក្នុង ឃុំព្រែកលួង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។ គេប្រើប្រាស់ចរបាប់គឺសម្រាប់កាត់សម្លៀកបំពាក់ប្រពៃណីក្នុងមង្គលការ និងពិធីមង្គលផ្សេងៗ ។ របៀបនៃការត្បាញចរបាប់នេះ គឺប្រហែលនឹងការត្បាញផាមួង ឬហូលដែរ ។ ចរបាប់មានក្បាច់ផ្កាផ្សេងៗ ដូចជា ផ្កាថ្កុល ផ្កាកន្ទួត ផ្កាច័ន្ទ ត្បូងពេជ្រ ជាដើម ។ មានប្រភេទសំពត់ដែលងាយច្រឡំនឹងចរបាប់គឺល្បើក ។ ល្បើកខុសពីចរបាប់ត្រង់ក្នុងចរបាប់ ផ្កាដែលគេពន្លេចឡើងគឺគេប្រើសែសយ ឯល្បើកវិញគេពន្លេចដោយប្រើសូត្រ ។ ចរបាប់ មានផ្កាច្រើនដែលអ្នកត្បាញខ្លះបានប្រាប់យើងថាមានរហូតដល់ទៅ ៦០ ផ្កា ។

# Chorabab

Nowadays, *chorabab* is only produced in Khsach Kandal district, Kandal Province. People use *chorabab* in wedding and blessing ceremonies. The way to produce *chorabab* is similar to how to make *hol* and *phamuong*. There are a few popular patterns such as *kantuot* flower, *chan* flower, and diamond. There is a kind of cloth similar to *chorabab* called lboek. *Lboek* is different from chorabab because *chorabab* uses sesoy to show up the pattern or flowers, but *lboek* uses silk instead. Weavers use a lot of *thkor* to produce *chorabab;* in some case they use sixty *thkor.*



*ចរបាប់ផ្កាច័ន្ទ*

*Corabab Phka Chan*

# សារុងសូត្រ

សារុងសូត្រជាសំពត់មួយប្រភេទដែលជនជាតិខ្មែរឥស្លាមនិយមចូលចិត្តប្រើ និងស្លៀកពាក់ ចូលរួមក្នុងពិធីធំៗទៀតផង ។ ធម្មតាសារុងសូត្រមិនមានក្បាច់ ឬគោមអ៊ុស្មុគ្រស្មាញទេ តាមរយៈការត្បាញកន្លងមក ។ សារុងសូត្រមានគោមដុំអាចម៍ជ្វា ដែលមានភាពល្បីគួរសម និងសារុងសូត្រសជាដើម ។



*គោម ដុំអាចម៍ជ្វា សារុង មកពីព្រែកចង្ក្រាន*

*Kom Dom Ach Jvea from Prek Changkran*



# Sarong Sotr

Khmer Muslims like to use and wear it not only at home but also in big ceremonies. The pattern of sarong is not complicated and has a few models like *dom ach cvea,* which is quite well-known and *sarong sotr.*



អ្នកតម្បាញ សារុងនៅភូមិ កោងទន្លេ ស្រុក កោះសូទិន

*Weaver in Koang Tole village, Koh Sotin District*



សារុងសូត្រស

*White sarong*



សារុងសូត្រពណ៌លឿង

*Yellow Sarong Sotr*

# ក្រមាសូត្រ

ក្រមាសូត្រប្រើសម្រាប់បង់ចូលរួមក្នុងពិធីផ្សេងៗ ។ ជាទូទៅប្រជាជនកម្ពុជាមានក្រមាប្រើប្រាស់យ៉ាងហោចណាស់មួយ ដែលស្ទើរតែទាំងអស់ធ្វើពីអំបោះសុទ្ធ ឬអំបោះលាយសូត្រ ។ ការប្រើប្រាស់ក្រមាជាទម្លាប់មួយនៃប្រជាជនយើង ។ ការត្បាញក្រមា និងសារុងសូត្រ គេប្រើតែថ្ករពីរ និងលឿនជាងការត្បាញហូល ឬចរបាប់ ។



# Scarf

Every person has at least one scarf *(krama)*. We mostly use scarves made from cotton and cotton-silk (more expensive). It is a part of Khmer tradition.





*ក្រមាសូត្រមកពីខេត្តតាកែវ*

*Krama from Takeo province*



# ពិដាន និងរនាំង

ពិដានត្រូវបានគេប្រើសម្រាប់តែក្នុងពិធីសាសនា ។ គោមដែលមាននៅលើពិដានមាន និយាយរៀបរាប់ពីពុទ្ធប្រវត្តិ ធម្មជាតិ ផ្កា សត្វហង្ស រូបស្រីអប្សរាជាដើម ។

វិធីសាស្ត្រនៃការធ្វើពិដាន គឺស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងការធ្វើហូល ព្រោះគេត្រូវយកសូត្រមកចងគាធ នឹងជ្រលក់ពណ៌ដូចគ្នាទៅនឹងដំណាក់កាលទាំងឡាយនៃការធ្វើហូល ។ សព្វថ្ងៃ ពិដានមានធ្វើនៅក្នុងស្រុកបាទី



*ពិដានមានរូបនាគមកពីខេត្តសៀមរាប*
*Picture of naga from Siem Reap*



*ពិដានរូបប្រាសាទនេះមានដាក់តាំងនៅអង្គការគាំពារកុមារខ្មែរខេត្តតាកែវ*
*Pidan at CYK, Bati district, Takeo province*

# Pidan and Roneang

This is used only in Buddhist ceremonies. The pattern on *pidan* illustrates the life of Buddha, nature, flowers, animals and Apsara.

The way to produce *pidan* or *roneang* is almost the same as the way we make *hol* because the silk has to be tied and dyed. It is currently only produced in Bati district, Takeo province.



*ពិដាននិយាយអំពីការចេញទៅបួសរបស់ព្រះពុទ្ធនេះមានដាក់តាំងនៅអគ្គការគាំពារកុមារខ្មែរ  ខេត្តតាកែវ*

*Pidan at CYK, Bati district, Takeo province*



# បញ្ជីពាក្យបច្ចេកទេសសំរាប់រុក្ខជាតិ

## ដកស្រង់ចេញពីវចនានុក្រមរុក្ខជាតិប្រើប្រាស់ក្នុងប្រទេសកម្ពុជា[១]

## *Listing of Technical word for plants Cited from planting Dictionary used in Cambodia*

| ល.រ<br>No | ឈ្មោះជាភាសាខ្មែរ<br>Khmer Name | ឈ្មោះជាភាសាឡាតាំង<br>Latin Name | លក្ខណៈជីវសាស្ត្រ<br>Biological features |
|---|---|---|---|
| ១<br>1 | សង្កែ | *combretum quadrangulare Kurz* | ឈ្មោះចុល្លព្រឹក្សមួយប្រភេទកំពស់២ ទៅ ១០ ម ដុះក្នុងព្រៃល្បោះ ទីវាលតាមមាត់ទឹក មានក្នុង ឧបទ្វីបឥណ្ឌូចិន (ប្រទេសថៃ ភូមា កម្ពុជា លាវ វៀតណាម) ។ ស្លឹកសង្កែគេដាក់ក្រោមពូក ឬ កន្ទេលឲ្យស្ងួតរាបល្អសម្រាប់មូរថ្នាំជក់ ។ ល័ខល្អ លេខ១ សម្រាប់ជ្រលក់សូត្រកើតលើដើមសង្កែនេះឯង ដោយសត្វម៉្យាងឈ្មោះ Carteria lacca ។ គ្រូពេទ្យបុរាណប្រើផ្លែសង្កែ សម្រាប់ឲ្យធ្លាក់ព្រូន ។ សំបកផ្សំជាមួយថ្នាំផ្សេងៗទៀត គេប្រើព្យាបាលដំបៅឃ្លង់ ។ ពេទ្យសត្វប្រើសំបកជាថ្នាំ កម្លាំងគោ និង សេះ ។<br><br>Shrub, 2-10 m tall, of secondary formations and deforested places, common along the rivers, species met in the Indochinese Peninsula (Thailand, Burma, Cambodia, Laos, Vietnam). The leaves, dried and well spread under mattes or mats, are used as cigarette paper. The plant may host lacquer insects (Carteria lacca), which make the lacquer-gum, natural dye for the silk. In traditional medicine, the fruits of (sângkaé) are used to remove ascaris. The bark is part of an ointment used to bandage the leperous ulcerations. The veterinary uses it as tonic for the oxen and the horses. |

[១] អ្នកគ្រូ ឌី ផុន បោះពុម្ព ឆ្នាំ ២០០០

| ល.រ No | ឈ្មោះជាភាសាខ្មែរ Khmer Name | ឈ្មោះជាភាសាឡាតាំង Latin Name | លក្ខណៈជីវសាស្ត្រ Biological features |
|---|---|---|---|
| ៧<br>2 | កកោះ | ***Sindora siam- ensis*** *Teijsm. ex Miq var. siamensis* | ព្រឹក្សមួយពូកកំពស់ ៦-១០ ម ដុះក្នុងព្រៃស្រោង ជាមួយសន្តានខ្ទង ត្បែង និងព្រៃល្បោះនៃឧបទ្វីប ឥណ្ឌូចិន និង ជ្វា ។ ផ្លែអាចបរិភោគបាន ពេលខ្លះគេស៊ីជាមួយស្លាម្លូ ។ គេអាចលីងគ្រាប់ដាំទឹកផឹក ដូចតែ ឬធ្វើចំណីផ្សេងៗ ឈើកកោះមានតំលៃណាស់ សម្រាប់ធ្វើគ្រឿងផ្ទះដូចជាក្តារ រនូត សរសរ ។ សំណល់ឈើ អាចប្រើធ្វើជាធ្យូងបាន ។ សំបកសម្រាប់ធ្វើថ្នាំ ជ្រលក់សំណាញ់ ។<br><br>Tree, 6-10 m tall, of the clear Dipterocarpus forests and secondary formations of the Indochinese and Malay Peninsula. The fruits are edible and chewed sometimes with the betel. The roasted seeds are used to make a tea like drink and is part of some desserts. Wood, graded its category, in demand for the constructions where it gives excellent floors, beams and columns. The by products of wood give a good coal. The bark is used to dyeing fishing nets. |

| លេ.រ<br>No | ឈ្មោះជាភាសាខ្មែរ<br>Khmer Name | ឈ្មោះជាភាសាឡាតាំង<br>Latin Name | លក្ខណៈជីវសាស្ត្រ<br>Biological features |
|---|---|---|---|
| ៣<br>3 | ត្រំ | *Indigofera tinctorial* | គុម្ពព្រឹក្សតូចមួយប្រភេទកំពស់ ៥០ ទៅ ៦០ ស.ម អាចដុះឯងៗក្នុងព្រៃស្រោង ឬដីវាលនៃឥណ្ឌូចិន គេច្រើនដាំជាដំណាំ ។ ស្លឹកវាសម្រាប់ជ្រលក់សំពត់ឲ្យ មានពណ៌ខ្មៅស្វាយតិចៗ ឬខ្មៅ ។ គ្រូបុរាណខ្មែរប្រើ ឬសត្រំធ្វើថ្នាំស្ទះនោម និងថ្នាំព្យាបាលជម្ងឺប្រមេះ ។<br><br>Sub-shrub, 50-60 cm tall, subspont-aneouse in the open formations and on the waste grounds of Indochina. The leaves supply a purple black dye. The roots are used in traditional Cambodian medicine against urinary retention and gonorrhea. |
| ៤<br>4 | អម្ពិលទឹក | ***Pithecellobium dulce*** *(Roxb.) Benth.* | ឈ្មោះ ឈើតូចមួយប្រភេទកំពស់ ៦ ទៅ ១០ ម កំណើតក្នុងទ្វីបអាមេរិចកណ្តាល គេនាំមកដាំនៅប្រទេសក្តៅនៃសកលលោក ។ គេច្រើនដាំធ្វើជារបងរស់ ។ សាច់ផ្លែរស់ចត់ល្មមបរិភោគ ។ ឈើដើមចាស់ៗ អាចប្រើធ្វើជាគ្រឿងផ្ទះបាន ។ សំបកអាចធ្វើថ្នាំរម្ងាប់រោគ ។ ស្លឹកចាស់ៗមានរស់ជាតិមួយដូចInsuline (ថ្នាំទឹកនោមផ្អែម) ។<br><br>Small tree, 6-10 m tall, originating from Central America, naturalized in all the tropical regions of the world, Species planted especially around houses to make quickset hedges. The arillus which wraps the seed is edible, eaten generally by the children, Wood of old trees may be used in construction. The colouring bark is used in traditional medicine. The old leaves contain a principle similar to the insulin. |

| លេខ.រ<br>No | ឈ្មោះជាភាសាខ្មែរ<br>Khmer Name | ឈ្មោះជាភាសាឡាតាំង<br>Latin Name | លក្ខណៈជីវសាស្ត្រ<br>Biological features |
|---|---|---|---|
| ៥<br>5 | គូលែន | ***Litchi chinensis* Sonn.** | ឈ្មោះព្រឹក្សមួយប្រភេទកំពស់ ៨ ទៅ ១០ ម ដុះ នៅប្រទេសចិនខាងត្បូង និង វៀតណាមខាងជើង ពូកជា នាំមកដាំជាយូរណាស់មកហើយគឺ ១៥ សតវត្សមុន គ.ស ។ នៅប្រទេសខ្មែរ គេឃើញដើមគូលែនដុះឯងៗ តែលើភ្នំគូលែនទេ ។ គេតែងដាំសម្រាប់យកផ្លែជាអាហារ ផ្លែស្រស់មានជីវជាតិ A និង B ជាច្រើន តែផ្លែក្រៀមគ្មានជីវជាតិនេះទេ ។ ផ្លែខ្ចីគេប្រើធ្វើថ្នាំអុតធំ ។ គ្រាប់ជាថ្នាំពោះវៀន ។ គ្រូថ្នាំបុរាណ ស្ងោរផ្កា សំបក និង ឫសគូលែនព្យាបាលជម្ងឺបំពង់ក ។<br><br>Tree, 8-10 m tall, originating from Southern China and Northern Vietnam introduced for cultivation in Malaysia towards 1500 B.C. In Cambodia, it is found in the spontaneous state on Phnom Kulen. Tree cultivated for its almost free arillus fruit. The fresh fruits are rich in A and B vitamins not found in dried fruits. The seed is used in traditional medicine against intestinal diseases. The green fruit is used against the smallpox. The decoctions of the flowers, barks and roots would be effective against the diseases of the throat. |

| ល.រ<br>No | ឈ្មោះជាភាសាខ្មែរ<br>Khmer Name | ឈ្មោះជាភាសាឡាតាំង<br>Latin Name | លក្ខណៈជីវសាស្ត្រ<br>Biological features |
|---|---|---|---|
| ៦<br>6 | ចេក | *Musal* | ចេកដែលជាដំណាំជាពូជបង្កាត់ច្រើនតំណណាស់ ហើយយើងពុំអាចឲ្យឈ្មោះវិទ្យាសាស្ត្របានឡើយ ។ ពូជដែលដុះក្នុងព្រៃមានផ្លែក្នុងគ្រាប់ជាច្រើន បរិភោគមិនបានទេ មានដុះនៅអាស៊ីផ្នែកអាគ្នេយ៍ ក្នុងប្រទេសឥណ្ឌាខាងកើត លើកោះសូម៉ាត្រា លើកោះយ៉ាវ៉ា ។ នៅប្រទេសខ្មែរមានចេកពូជបង្កាត់ច្រើនណាស់ ចេកណាំវ៉ា ចេកពងមាន់ ចេកស្នាប់មុខ ចេកជ្វា ។ល ។ ចេកជ្វា មានគ្រាប់តែបរិភោគបាន ។ ដើមចេកនិងគល់គេច្រើនប្រើជាចំណីជ្រូក តែមនុស្សក៏បរិភោគបានដែរ ។ ផ្កា(ត្រយូងចេក) ប្រើធ្វើបន្លែ ឬអន្លក់ ។ល ។<br><br>All the cultivated banana trees are hybrids repeated natural crossings the parents of which became not recognizable The first wild banana trees, with fruits full of seeds, are numerous. The main of these are Musa acuminata Colla, born somewhere in Southeast Asia, Musa balbi siana Colla, born, in the oriental part of India the Musa halabanensis Meijer, born in the western part of Sumatra and Musa salaccensis Zoll. native either of Sumatra or Java. |

| ល.រ No | ឈ្មោះជាភាសាខ្មែរ Khmer Name | ឈ្មោះជាភាសាឡាតាំង Latin Name | លក្ខណៈជីវសាស្ត្រ Biological features |
|---|---|---|---|
| | | | In Cambodia there is a very large number of cultivated species “chék nam’va” “chék pong moën” (hen’s egg banana tree) “chék âmbông” ”chék nuon” chék snab muk chék chhvie (Malay banana tree) This last one has fruits still provided with seeds but edible while those of the wild banana trees are not.<br><br>The leaves of banana trees are used as packaging to wrap goods various cakes, rice etc. The trunk is edible as well as the tree stumps At normal time, they are used to feed pigs The young inflorescences “trâyông chék” freed of their large coloured bracts, are much valued as vegetables. |
| ៧ 7 | អម្ពិលបារាំង | ***Albizia saman (Jack) F.Muell*** | អម្ពិលបារាំងជារុក្ខជាតិមានដើមកំណើតក្នុងស្រុក អាមេរិកក្ដៅ ។ គេដាំនៅស្រុកអាហ្វ្រិច និង អាស៊ីជា លំអតាមផ្លូវ ឬសម្រាប់ម្លប់ជ្រកជិតផ្ទះ ។ ស្លឹកខ្ចីៗ អាចធ្វើអន្លក់ពេលទុរ្ភិក្ស ។ ផ្លែក៏បរិភោគបានដែរ ។<br><br>Rain tree has its origin in tropical America cultivated in Asia and Africa as ornamental and as shade tree In time of shortage the young leaves has been eaten in salads The fruit is edible |

| លេ.រ No | ឈ្មោះជាភាសាខ្មែរ Khmer Name | ឈ្មោះជាភាសាឡាតាំង Latin Name | លក្ខណៈជីវសាស្ត្រ Biological features |
|---|---|---|---|
| ៨<br>8 | ខ្នុរ | ***Artocarpus heterophyllus Lam.*** | ខ្នុរ ជាដើមឈើតូចមានដើមកំណើតនៅប្រទេសជ្វា គេតែងដាំរុក្ខជាតិនេះពាសពេញប្រទេសអាស៊ីផ្នែកក្ដៅ ។ ផ្លែខ្នុរមានរសជាតិឆ្ងាញ់ណាស់ ។ មានដាក់លក់ក្នុងផ្សារ ស្រុកខ្មែរគេលក់ផ្លែទាំងមូល ឬចិតជាចំណិត ។ នៅបរទេសមានសាច់ខ្នុរលក់ជាអាហារប្រអប់ ។ ដើមខ្នុរ គេយកធ្វើ តុ ទូ និង គ្រឿងភ្លេង ។<br>Small tree native to Malaya cultivated everywhere in the tropic for its edible fruits which may be sold on markets fresh or in preserve. Seeds rich in fecule are edible boiled or fired. Jack wood is used for furniture and for manufacture of music instruments. |
| ៩<br>9 | ស្ដៅ | ***Aglaia leptantha Mig*** | ស្ដៅភ្នំជាដើមឈើកំពស់ពី ២០-៣០ ម ច្រើនដុះលើភ្នំក្នុងប្រទេសខ្មែរ និង វៀតណាមខាងត្បូង ។ ស្លឹក និងផ្កាខ្ចីអាចបរិភោគបានដូចស្ដៅធម្មតាដែរ ។ ឈើពណ៌ ក្រហមមានក្លិនក្រអូប លក់បានតំលៃណាស់ ។ គេប្រើឈើស្ដៅភ្នំជំនួស ច័ន្ទគ្រឹស្នាបានខ្លះៗ ។ គ្រូថ្នាំយកសំបក ទៅស្ងោរដើម្បីឲ្យអ្នកមានជំងឺគ្រុនផឹក ។ ពេទ្យសត្វ ស្ងោរសំបកឲ្យគោ ក្របីផឹកដើម្បីឲ្យវាស៊ីស្មៅបានច្រើនឆាប់ធាត់ធំ ។ |

| លរ / No | ឈ្មោះជាភាសាខ្មែរ / Khmer Name | ឈ្មោះជាភាសាឡាតាំង / Latin Name | លក្ខណៈជីវសាស្ត្រ / Biological features |
|---|---|---|---|
| | | | Tree, 20-35 m tall restricted to mountain forest in Cambodia and in south-Vietnam Yong leaves and flowers are eaten in salads, like that of the genuine "Sdau" (Azadiracta indica) Red wood , fragrant used as incense like the genuine santal wood In local medicine the bark decoction is drunk against fever The same decoction given to oxes or buffaloes may increase their appetite. |
| ១០<br>10 | ដូង | ***Cocos nuciferal.*** | ឈ្មោះព្រឹក្សម៉្សាងសន្តាន ស្វា គ្មោត កំពស់ ២-៣០ ម មានដើមកំណើតក្នុងទ្វីបអាស៊ីគេស្គាល់ដូងជិត ៤ ពាន់ឆ្នាំហើយនៅប្រទេសចិន (ក្នុងកំណាព្យចិនមួយ គេឃើញមានឈ្មោះដូង កំណាព្យសរសេរប្រហែល ២ ពាន់ឆ្នាំមុនព្រះយេស៊ូ) ។ ដូងមានច្រើនប្រទេសណាស់ តែឈ្មោះវិទ្យាសាស្ត្រនៅដដែលមានដូងភ្លើង ដូងតឹកកែ ដូងខ្ទិះ ដូងសម្ល ។ល ។ ដើមដូងប្រយោជន៍ណាស់ ស្លឹកសម្រាប់ធ្វើដំបូលផ្ទះឬសង់រោងធ្វើបុណ្យ ។ល ។ ផ្កាដូង ពេលខ្លះគេប្រើជំនួសផ្កាស្លា ក្នុងពិធីអាពាហ៍ពិពាហ៍ ។ ផ្លែគេប្រើបានច្រើនប្រភេទណាស់ ទឹកដូងជាភេសជ្ជៈល្អណាស់ សាច់ដូងខ្ចីគេបរិភោគជាមួយទឹកសាច់ចាស់ច្របាច់យកខ្ទិះស្ល ធ្វើបង្អែមផ្សេងៗ |

| លរ<br>No | ឈ្មោះជាភាសាខ្មែរ<br>Khmer Name | ឈ្មោះជាភាសាឡាតាំង<br>Latin Name | លក្ខណៈជីវសាស្ត្រ<br>Biological features |
|---|---|---|---|
| | | | ឬស្ងោរ ធ្វើប្រេង ។ ស្រកីដូងគេតែងយកធ្វើអំបោស ។ ពេទ្យបុរាណប្រើឫសដូង សម្រាប់ផ្សំថ្នាំព្យាបាលជម្ងឺរាគមូល ។ ត្រឡោកដូងគេដុតក្នុងផេះក្តៅឲ្យចេញជ័រ ជ័រនេះប្រើសម្រាប់លាបឲ្យបាត់ឈឺធ្មេញ ។<br><br>Tree, 2-30 m tall, monocaulous, of Asian origin, cultivated at present in the warm countries of the world. It appeared some 4000 year ago (the1st mention of a coconut palm in China is found in a Chinese poem of the 20th century B.C) There are numerous varieties or cultivated forms.<br><br>All the parts of the coconut palm are useful. The leaves are used for covering the houses or for decorating climbing frames and meeting rooms. The flowers are sometimes used in the wedding ceremonies. The most used part is the fruit, or coconut which water (liquic albumen) makes a soft drink. The copra (solid albumen) gives an oil with multiple uses (cooking, cosmetic...) The fibrous envelope of the fruit is used generally to make brooms. In traditional medicine, the roots of the coconut palm are said to be to effective against dysentery. The nut freed of its fibers, burned on warm ashes let exudate an oily material used to calm dental pains. |

| លេ.រ No | ឈ្មោះជាភាសាខ្មែរ Khmer Name | ឈ្មោះជាភាសាឡាតាំង Latin Name | លក្ខណៈជីវសាស្ត្រ Biological features |
|---|---|---|---|
| ១១ 11 | នននោង | ***Luffa acutangula (L) Roxb*** | ឈ្មោះវល្លិដំណាំឡើងទ្រើង កំណើតនៅក្នុងប្រទេសឥណ្ឌា គេដាំយកផ្លែជាអាហារ ផ្លែរាងដូចមោងមាន ១០ ជ្រុងស្រួចៗ គេប្រើផ្លែធ្វើម្ហូបបានច្រើនមុខ ។ ក្នុងក្បួនឱសថបុរាណគេបុកស្លឹកបំពោកលើមុខរបួសឲ្យឆាប់ជា ។ ផ្លែជាថ្នាំធ្វើឲ្យនោមច្រើន ។<br><br>Liana, vague origin, cultivated in all tropical regions of the world, for the fruits cylindrical. edible used as vegetable in various culinary preparations The dried out ripe fruits are used as sponges In traditional medical, the leaves are used in external application against the hurts of shingles. The fruits could favor the milky secretion of young mothers and activate the blood circulation. The roots are said to be purgative. |
| ១២ 12 | ជម្ពូជ្រលក់ | ***Bixa orellanal*** | ដើមនេះជាចុល្លព្រឹក្សមានកំពស់ ២ ទៅ ៨ម គេនាំពី ស្រុកអាមេរិចក្ដៅ យកមកដាំជុំវិញគេហដ្ឋានឲ្យល្អមើល ។ គ្រាប់ជម្ពូជ្រលក់មានជាតិពណ៌ក្រហម លាយពណ៌លឿងភ្លាវសំរាប់ជ្រលក់សំពត់អាវប្ញរបស់ ផ្សេងៗ ។ ស្លឹកគេដាំទឹកផ្ទូត ឬត្រាំពេលកើតជំងឺគ្រុនចាញ់ គ្រុនមានពិសស្បែក ឬគ្រុនក្ដៅផ្សេងៗ ។ |

| ល.រ<br>No | ឈ្មោះជាភាសាខ្មែរ<br>Khmer Name | ឈ្មោះជាភាសាឡាតាំង<br>Latin Name | លក្ខណៈជីវសាស្ត្រ<br>Biological features |
|---|---|---|---|
| | | | Shrub. 2-8 m tall, native to tropical America, introduced to Cambodia, cultivated near dwelling as decorative plant. The seeds yield a red colouring used as stain. In traditional medicine, the leaves have the reputation, while used for lotions or baths, to be effective against paludism eruptive fever and other forms of fever. |
| ១៣<br>13 | មន | ***Morus albal*** | ចុល្លព្រឹក្សកំពស់ ៣ ទៅ ៧ ម នាំពីស្រុកចិនកណ្តាល និងខាងលិចមកដាំគ្រប់ប្រទេសនៃអាស៊ីផ្នែកអាគ្នេយ៍ ទ្វីបអឺរ៉ុប និង អាមេរិកខាងជើង ។ ដើមជាពូជបន្ទាត់ពី ពូជមនធំគេដាំសម្រាប់យកស្លឹក ប្រើជាចំណីដង្កូវនាងធ្វើសូត្រ ។ គ្រូថ្នាំបុរាណប្រើស្លឹកមនធំ ផ្សំធ្វើថ្នាំព្យាបាល ជម្ងឺភ្នែកក្រហម និងសម្រាប់លាងដំបៅផ្សេងៗ ។ សំបកជាថ្នាំកម្លាំងនិងទប់មិនអោយរាគជាដើម ។<br><br>Shrub, 3-7 m tall, originating from the central and oriental part of China, introduced and naturalized in Southeast Asia, Europe and North America. Varieties of this species are used for the breed of silkworms (Bombyx mori). In traditional medicine, the leaves are a component of a remedy against the conjunctivitis. The are also used for the treatment of the wounds. The barks are considered as fortifying and astringent. |

| លេ.រ<br>No | ឈ្មោះជាភាសាខ្មែរ<br>Khmer Name | ឈ្មោះជាភាសាឡាតាំង<br>Latin Name | លក្ខណៈជីវសាស្ត្រ<br>Biological features |
|---|---|---|---|
| ១៤<br>14 | ព្រហូត | ***Garcinia vilersiana Pierre*** | ព្រហូតជាព្រឹក្សកំពស់ ១០ ទៅ ១៥ ម ដុះក្នុង ព្រៃក្រាស់នៃប្រទេសថៃ ខ្មែរ លាវ និង វៀតណាមខាង ត្បូង ។ សំបកសម្រាប់ធ្វើថ្នាំជ្រលក់សំពត់ល្អប្រណិត ឲ្យមានពណ៌លឿង ។ គ្រូហ្មខ្មែរយកសំបកព្រហូត លាយជាមួយសំបកទ្រមូង ធ្វើថ្នាំបំពោកលើដៃជើងគ្រេច ។ ឈើមានពណ៌ ស លឿងប្រើសម្រាប់សង់ផ្ទះ ។<br>Tree, 10-15 m tall, originating from the dense forests of Thailand, Cambodia, Laos and Southern Vietnam. The bark gives the best yellow dye of Southeast Asia. In traditional Khmer medicine, the barks, associated to those of “tromu: ng” (G. oilveri Peter) are used to make poultices applied on the sprains. The wood, white yellowish, is used for construction. |
| ១៥<br>15 | អម្ពិល | ***Tamarindus indical*** | ព្រឹក្សតូចម៉្យាងកំពស់ ៨ ទៅ ១៥ ម ដើមកំណើតក្នុង ទ្វីបអាហ្វ្រិក ឬប្រទេសឥណ្ឌា គេនិយមដាំនៅ គ្រប់ ប្រទេសក្ដៅនៃសកលលោក ជារុក្ខជាតិមានប្រយោជន៍ នឹង ឲ្យម្លប់ផង ។ ស្លឹកខ្ចីៗ និង ផ្លែគេប្រើសម្រាប់ធ្វើគ្រឿងទេសជូរ ។ គ្រាប់អាចលីងនិងធ្វើបង្អែមបាន ។ ឈើសម្រាប់សង់ផ្ទះ ។ គេស្ងោរសំបកផឹកជាថ្នាំរាគ ។ មានពូជអម្ពិលផ្អែមច្រើនដុះក្នុងប្រទេសថៃ ។ |

| លរ No | ឈ្មោះជាភាសាខ្មែរ Khmer Name | ឈ្មោះជាភាសាឡាតាំង Latin Name | លក្ខណៈជីវសាស្ត្រ Biological features |
|---|---|---|---|
| | | | Small tree, 8-15 m tall, originating from India or Africa, cultivated in all tropical regions of the world as shadow, decorative and utilitarian plant. The young leaves and fruits are used in culinary preparations as acid elements. The seeds are used to cook a sweet dishes. Wood is used in construction. The decoction of the barks would be effective against diarrhoea. This is a variety of tamarind with sweet fruits met especially in Thailand. |
| ១៦<br>16 | ស្នួល | ***Dalbergia nigrescens Kurz var. saigonensis (pierre) Gagnep.*** | ឈ្មោះព្រឹក្សមួយប្រភេទកំពស់ ១០ ទៅ ២០ ម ដុះក្នុង ព្រៃស្រោង និង ព្រៃល្បោះ ក្នុងទ្វីបឥណ្ឌូចិន ។ ផ្លែខ្ចីៗ អាចបរិភោគបាន ។ គ្រាប់ទុំគេលីងហើយកិនឲ្យម៉ត់ ឆុងផឹកដូចកាហ្វេ ។ ឈើស្នួលគេប្រើ សម្រាប់សង់ផ្ទះ និងធ្វើវត្ថុផ្សេងៗ ។<br><br>The roasted seeds give a drink evoking coffee. The wood is used in woodwork. In traditional medicine, the leaves crushed with salt are used to heal the wounds of oxen (caused by the yoke) the old leaves give a black paint. |

| លេ.រ No | ឈ្មោះជាភាសាខ្មែរ Khmer Name | ឈ្មោះជាភាសាឡាតាំង Latin Name | លក្ខណៈជីវសាស្ត្រ Biological features |
|---|---|---|---|
| ១៧ 17 | ផ្ទីបន្លា | ***Amaranthus spinosusl.*** | ជាស្មៅប្រចាំឆ្នាំដុះជិតផ្ទះក្នុងប្រទេសក្តៅសកលលោក ។ ស្លឹក និងធាងខ្ចីគេយកធ្វើសម្ល ឬឆា ដូចផ្ទីធំដែរ ។ ស្លឹក និងឫស សម្រាប់ធ្វើថ្នាំរំងាប់រោគផ្សេងៗ ក៏បានគេយកឫសស្ងោរលាយទងត្នោតឲ្យខាប់មែនទែន ដើម្បីយកមកស្អំរំងាប់រោគសន្លាក់ឆ្អឹង ឬរោគស្បូន ។ គេបុកអោយល្អិតធ្វើថ្នាំបំពោកលើរបួសឆ្កែខាំ ។<br><br>Annual herb which grows near villages in tropics. Young leaves are eaten like spinach. Leaves and roots are often used as poultices to cure some wounds, especially those caused by dog bite. The roots infusion would be diuretic. Associate with “thnot” roots (Borassus flabellifer) the roots are used as poultices against rheumatism and some forms of tuberculosis. |

# សទ្ទានុក្រមតម្បាញ
# Technical terms

| លរ No | មេពាក្យ Primary word | ថ្នាក់ Class | សេចក្តីពន្យល់ Explanation | យោង Reference |
|---|---|---|---|---|
| ១ | កកី | ន | ជាវត្ថុមួយរបស់កីតម្បាញ សម្រាប់ទ្រឈើផ្ញុំដែលស្ថិតនៅត្រង់ក្បាលកី | គង់ គន្ធារី ១៩៩៤ |
| 1 | Loom neck | n. | A loom tool, used to support joined wood, which is placed at the head of the loom. | |
| ២ | កី | ន | ឧបករណ៍សម្រាប់ត្បាញ ហូល ផាមួង ក្រមា ឬសំពត់ជាដើម | គង់ គន្ធារី ១៩៩៤ |
| 2 | Loom | n. | A tool, used to weave hol, phamuong, scarves or clothes | |
| ៣ | កីហូត | ន | ជាឧបករណ៍សម្រាប់ត្បាញ ដែលគេតម្លើងវាដោយប្រើវីស | គង់ គន្ធារី ១៩៩៤ |
| 3 | Drawing loom | n. | A weaving tool which is assembled using screws. | |
| ៤ | កូនហក់ | ន | ជាឧបករណ៍មួយធ្វើអំពីឈើ ឬក៏ឫស្សីមួយវែង ដែលមាន ស្រយូវសម្រាប់ស៊កសរសៃសូត្រនៅពេលអន្ទង | គង់ គន្ធារី ១៩៩៤ |
| 4 | Konhoak | n. | A long wooden or bamboo tool which contains a ring to insert silk during the weaving process. | |
| ៥ | កូនកំព្រា | ន | កង់ ឬកំណាត់ឫស្សីសម្រាប់ស៊ក នឹងព្រ័ត្រខ្សែវល្លិ៍ អំបោះ ហើយមួលរឹតឲ្យតឹង ឬឲ្យមាំ | គង់ គន្ធារី ១៩៩៤ |
| 5 | Konkampria (orphan) | n. | A piece of bamboo inserted with vine or silk and tied firmly. | |
| ៦ | កូនអន្ទង | ន | កូនឈើ ឬដែកតូចៗ ដែលគេដាំនឹងបន្ទះឈើធំសម្រាប់ថ្លក់អំបោះអន្ទង | ជា ពិសី ១៩៩៤ |
| | Konangtorng | n. | A small strip of wood or metal which has a big wood plank, used to weave silk. | |

| លរ No | មេពាក្យ Primary word | ថ្នាក់ Class | សេចក្តីពន្យល់ Explanation | យោង Reference |
|---|---|---|---|---|
| ៧ | កួត | កិ | ធ្វើឲ្យស្ងាប់សាច់ ធ្វើឲ្យរាបទាបៈ កួតអំបោះ | ជា ពិសី ១៩៩៤ |
| 7 | Kuot | v. | To flatten; to smooth | |
| ៨ | កូយ | ន | ជាពាក្យរបស់អ្នកស្រុកនិយមហៅនៅពេលដែលដង្កូវនាងធំទុំ | គង់ គន្ធារី ១៩៩៤ |
| 8 | Koy | n. | A dialect word people used to call a silkworm when it has already produced a cocoon. | |
| ៩ | កាំបិតស្លា | ន | គឺជាពាក្យមួយដែលគេសម្គាល់កាំបិតបត់ ប្រើប្រាស់ក្នុងការត្បាញ | គង់ គន្ធារី ១៩៩៤ |
| 9 | Areca knife | n. | A type of knife (fold knife) used in weaving. | |
| ១០ | កន្ទុយកី ឬ ចុងកី | ន | ផ្នែកខាងក្រោយនៃកីត្រង់កន្លែងក្តារមូរអំបោះ | ជា ពិសី ១៩៩៤ |
| 10 | Loom rear | n. | The back of the loom which is placed at the thread rolling board. | |
| ១១ | ក្តាតង្ករ ឬ ក្តារថ្ករ | ន | ជាបន្ទះឈើតូចល្មមសម្រាប់ក្រងប្រទាក់អំបោះនៅថ្ករមុនពេលត្បាញ | ជា ពិសី ១៩៩៤ |
| 11 | Thkor board | n. | A medium board, used to braid silk before weaving. | |
| ១២ | ក្តារមូរ | ន | ជាបន្ទះឈើសំប៉ែតវែងល្មម ប្រើសម្រាប់មូរសសៃអំបោះដែលអន្ទងហើយ | ជា ពិសី ១៩៩៤ |
| 12 | Rolling board | n. | A wooden board (of medium length), used to roll up silk that has already been woven. | |

| ល.រ No | មេពាក្យ Primary word | ថ្នាក់ Class | សេចក្តីពន្យល់ Explanation | យោង Reference |
|---|---|---|---|---|
| ១៣ | ក្តារគោះគី | ន | សម្រាប់គោះនៅពេលដែលបោះត្រល់ឲ្យរត់ម្ដងៗ ហើយ ដើម្បីឲ្យសាច់ក្រមា ឬសំពត់ហាប់ | ជា ពិសី ១៩៩៤ |
| 13 | Kuoh Key board | n. | A wooden board, use to knock scarf or cloth to make it well stuffed. | |
| ១៤ | ក្បាលគី | ន | ផ្នែកខាងដើមនៃគីត្រង់កន្លែងដែលអ្នកត្បាញ | គង់ គន្ធារី ១៩៩៤ |
| 14 | Head of the loom | n. | The beginning part of the loom where the weaver sits. | |
| ១៥ | ក្បិន | ន | គឺជាកន្ទុយសំពត់ៗ ពេលណាដែលគេនិយាយថា ស្លៀកសំពត់ចងក្បិន គឺមានន័យថា គេមូរជាយសំពត់ចុកមកខាងលើ | គង់ គន្ធារី ១៩៩៤ |
| 15 | Kbin | n. | The cloth measure, also a kind of Khmer clothing. | |
| ១៦ | ក្រមា | ន | ជាសំពត់ត្បាញដោយអំបោះ មានក្រឡា ខ្វែង សម្រាប់ផ្លាស់ងូតទឹក | ជា ពិសី ១៩៩៤ |
| 16 | Scarf | n. | A kind of cloth, made from cotton or silk and woven with a checked pattern, which is used for bathing. | |
| ១៧ | ក្រោះ | គុ | ស្ងួតបួង ក្រៀមក្រទាំង | គង់ គន្ធារី ១៩៩៤ |
| 17 | Armor | adj. | Dry (not humid) | |
| ១៨ | ខ្នារ | ន | ប្រដាប់សម្រាប់ខារអំបោះ ឬសូត្រ | ជា ពិសី ១៩៩៤ |
| 18 | khnar | n. | A tool used to roll up silk for weaving. | |

| ល.រ No | មេពាក្យ Primary word | ថ្នាក់ Class | សេចក្តីពន្យល់ Explanation | យោង Reference |
|---|---|---|---|---|
| ១៩ | គម្របផ្ទេញឈើ | ន | ជាបន្ទះក្តារមានក្បាច់នៅចុងសងខាង រាងជាកន្ទុយហង្សសម្រាប់គាបផ្ទេញឈើឲ្យតឹងមាំ | ជា ពិសី ១៩៩៤ |
| 19 | Cover of wooden comb | n. | A plank with hang (mythical bird)-tail decorations on both sides, used for pressing the comb firmly. | |
| ២០ | ឃ្លេ | ន | ឈ្មោះដើមរនាមមួយប្រភេទមានបន្លា សម្រាប់យកខ្ទឹមស្ងោរជ្រលក់សូត្រ | គង់ គន្ធារី ១៩៩៤ |
| 20 | Khle | n. | A name of a thorny tree in flood forest, whose leaves are boiled to create a silk dye. | |
| ២១ | ចាងណាង | ន | ជាសម្ភារៈម្យ៉ាងដែលគេព្យួរចន្លោះដូរតង្កររហើយនឹងរ៉ក | គង់ គន្ធារី ១៩៩៤ |
| 21 | Chang-Nang | n. | A tool which is hung between the dangkor and the pulley. | |
| ២២ | ចំពួច | ន | ជាពាក្យអ្នកស្រុកហៅ គឺមានន័យថាអំបោះមួយដុំ ដែលបានពីការរវៃក្នុងរហាត់កុង តែសព្វថ្ងៃអំបោះដុំតូចៗ ប៉ុនម្រាមដៃដែលគេចងចុងក៏គេហៅថាចំពួចដែរ | ជា ពិសី ១៩៩៤ |
| 22 | Champuoch | n. | A pice of cotton or silk threads after spinned, but today a piece of cotton thread as big as a thumb, with its end tied is also called champuoch too. | |
| ២៣ | ជរជាយ | ន | ពាក្យនេះសម្គាល់ជាយសំពត់ផាមួង ដែលគេលម្អរចនាប្លែកពីផ្ទៃកណ្តាលនៃសំពត់ | គង់ គន្ធារី ១៩៩៤ |
| 23 | Hem decoration | n. | This is used so you notice the hem of phamuong, which is decorated in a pattern different from the main section. | |

| លេខរៀង (ល.រ)<br>No | មេពាក្យ<br>Primary word | ថ្នាក់<br>Class | សេចក្តីពន្យល់<br>Explanation | យោង<br>Reference |
|---|---|---|---|---|
| ២៤<br>24 | ជើងគី<br>Loom foot | ន<br>n. | គឺជាឈើ ៤ កំណាត់ សម្រាប់ទ្រមេគី<br>The four pieces of wood to support the loom. | គង់ គន្ធារី ១៩៩៤ |
| ២៥<br>25 | ជន្ទាល់<br>Supportter | ន<br>n. | ប្រើសម្រាប់ខ្វាស់ញែកក្រមា ឬសំពត់ ដែលត្បាញបានឲ្យតឹងល្អ<br>A tool used to separate a woven scarf or cloth. | ជា ពិសី ១៩៩៤ |
| ២៦<br>26 | ឈើកោះ<br>Koh wood | ន<br>n. | ជាឈើមួយដុំ ដូចឈើផ្ទំ ដែលមានស្រយូវ៤ ។ គេប្រើវាជំនួសឈើផ្ទំ នៅពេលចាប់ផ្តើមត្បាញដំបូង<br>A piece of wood, like joined wood, which has four rings. It is used to replace joined wood when the weaving starts. | គង់ គន្ធារី ១៩៩៤ |
| ២៧<br>27 | ឈើដំរឹង<br>Damroeung wood | ន<br>n. | ឈើដំរឹងរបស់កីតម្បាញមាន ៤ ដែលគេប្រើប្រាស់សម្រាប់ទ្រធ្នឹង<br>There are four damroeung wood to support the crossbar. | គង់ គន្ធារី ១៩៩៤ |
| ២៨ | ឈើធ្នឹម<br>Wooden crossbar | ន<br>n. | គឺឈើមួយកំណាត់សម្រាប់ទប់ខ្សែឆ្នារ ។ ប្រើជាប់នឹង ជើងទ្រទាំងបួនរបស់កី ជាជំនួយឲ្យរឹងមាំ និងទ្រឈើរា សម្រាប់រុញថ្កូរទៅមុខ ឬថយក្រោយ<br>A piece of wood to obstruct fine threads, used with a four-foot loom in order to make it firmer to support rea wood to push the thkor back and forwards. | គង់ គន្ធារី ១៩៩៤ |

| លរ <br> No | មេពាក្យ <br> Primary word | ថ្នាក់ <br> Class | សេចក្ដីពន្យល់ <br> Explanation | យោង <br> Reference |
|---|---|---|---|---|
| ២៩ | ឈើរឹត | ន | គឺជាកំណាត់ឈើមូលវែងមួយដើម ដាក់នៅខាងចុងកី ដែលផ្ទុកជាប់នឹងក្ដាររមូរដោយខ្នោះដែក ២ ។ ប្រើសម្រាប់រឹតសរសៃអំបោះដែលមូរបញ្ចូលក្ដារ ដែលនៅកន្ទុយកីនោះឲ្យតឹងល្អ | គង់ គន្ធារី ១៩៩៤ |
| 29 | Wooden tightening tool | n. | A long round piece of wood placed at the end of loom, hooked with rolling wood with two iron shackles. The weaver uses it to tighten the silk in the rolling wood at the loom tail. | |
| ៣០ | ឈើរា | ន | ជាគ្រឿងត្បាញធ្វើពីឫស្សីប្រើនៅពេលមូរអំបោះបែបសម័យបុរាណ ដើម្បីជាជំនួយឲ្យសរសៃអំបោះតឹងល្អ និងប្រើនៅពេលត្បាញជាគ្រឿងគន្លងដែលដាក់លើឈើ ធ្នឹម | ជា ពិសី ១៩៩៤ |
| 30 | Rea wood | n. | A weaving tool, made of bamboo, in the past used to roll up silk to tighten it; and is the dangkor tool, which is put on the crossbar. | |
| ៣១ | ឈើផ្សំ | ន | គ្រឿងប្រដាប់ សម្រាប់មូរក្រមា ឬសំពត់ស្បៃ ដែលត្បាញបាន គេហៅម្យ៉ាងទៀតថាផ្សំមូរ | ជា ពិសី ១៩៩៤ |
| 31 | Joined wood | n. | A tool to roll up a scarf or cloth which has already been woven, also called phsam-mou. | |
| ៣២ | ឈើឈ្នាន់ | ន | ឈើសម្រាប់ជាន់ ឲ្យគន្លងបើកបិទ | ជា ពិសី ១៩៩៤ |
| | Pedal wood | n. | A wooden pedal to control the dangkor (open and close). | |

| លរ No | មេពាក្យ Primary word | ថ្នាក់ Class | សេចក្ដីពន្យល់ Explanation | យោង Reference |
|---|---|---|---|---|
| ៣៣ | ឈើ ប្ដងអន្ទង | ន | ឈើសម្រាប់អន្ទងអំបោះ ឬសូត្រ "បុរាណ" | ជា ពិសី ១៩៩៤ |
| 33 | Woven wood | n. | A wooden tool was used to weave cotton and silk in the past. | |
| ៣៤ | ដាម | ន | ឈ្មោះគ្រឿងតម្បាញមានសណ្ឋានដមសំប៉ែតវែង សម្រាប់សឹកខ្វាស់អំបោះ ឬសូត្រអន្ទង ញែកមុខកុំឲ្យ ព័ន្ធប្រឡំគ្នា ឬហៅម៉្យាងទៀតថា ដាមសំប៉ែត | ជា ពិសី ១៩៩៤ |
| 34 | Streaking wood | n. | A long and flat weaving tool used to insert and divide silk from side to side. It is also called flat streaking wood. | |
| ៣៥ | ដាមកំណើត | ន | គឺជាដាមដែលធ្វើអំពីឫស្សីយ៉ាងស្ដើង ដែលគេប្រើប្រាស់វាសម្រាប់ទប់គ្រោះតម្បាញ | គង់ គន្ធារី ១៩៩៤ |
| 35 | Original streaking wood | n. | A thin tool made of bamboo used to obstruct kroh. | |
| ៣៦ | ដាមមូរ | ន | គឺជាដាមដែលធ្វើអំពីឫស្សី ឬ ឈើ ហើយដែលស្ថិតនៅខាងចុងនៃកីតម្បាញ | គង់ គន្ធារី ១៩៩៤ |
| 36 | Round streaking wood | n. | A tool made of wood or bamboo, placed at the end of the loom. | |
| ៣៧ | ដាមរើស | ន | ជាដាមម៉្យាង ដែលធ្វើអំពីបន្ទះឫស្សីស្ដើងៗ គេប្រើប្រាស់ វាសម្រាប់រើសសរសៃសូត្រ យកទៅថ្កូរ | គង់ គន្ធារី ១៩៩៤ |
| 37 | Select streaking wood | n. | A thin tool made of bamboo used to select silk threads. | |

| លេ.រ<br>No | មេពាក្យ<br>Primary word | ថ្នាក់<br>Class | សេចក្តីពន្យល់<br>Explanation | យោង<br>Reference |
|---|---|---|---|---|
| ៣៨ | ដាមនាំ | ន | គឺមានសណ្ឋានដូចជាដាមមូរដែរ ដែលគេប្រើវានៅក្នុងពេលត្បាញ នៅពេលដែរគេត្រូវការមូរ ។ សម្រាប់ប្រើ ពេលមូរអំបោះអន្ទង គេនាំដាមសំប៉ែតទៅមុខមុន និងមូរកុំឲ្យជំពាក់ | គង់ គន្ធារី ១៩៩៤ |
| 38 | Guide streaking wood | n. | This is similar to round streaking wood, and is used in weaving when the weaver needs to roll up silk. The weaver first brings guide streaking wood then rolls up silk to avoid tangling. | |
| ៣៩ | ថាន | ន | ជាផ្ទៃអំបោះលាតស្មើដែលនៅលើកី | ជា ពិសី ១៩៩៤ |
| 39 | Tharn | n. | This is the even silk surface in the loom. | |
| ៤០ | តង្កូវ | ន | ខ្សែអំបោះឆ្មារសម្រាប់ថ្កូវត្បាញ | ជា ពិសី ១៩៩៤ |
| 40 | Dangkor | n. | A fine thread, used for thkor. | |
| ៤១ | តម្បាញ | កិ | ខ្វាស់ចេសអំបោះឲ្យកើតជាសំពត់ ឬខ្វាស់អ្វីៗឲ្យកើតជា ល្អី កញ្ជើ ... | ជា ពិសី ១៩៩៤ |
| 41 | Weaving | v. | Mix threads or other things to make clothes, baskets, bags, etc. | |
| ៤២ | ត្រដោកក្តារ | កិ | ប្រើសម្រាប់ជួយទប់ឈើរីត នឹងកន្ទុយកីឲ្យក្តារមូរ ឬហុងមូរតឹងមិនរអិល | ជា ពិសី ១៩៩៤ |
| 42 | Wooden wedge | v. | This is used to help tighten wood and the loom rear to keep the rolling board or spool from slipping around. | |



| លេ.រ No | មេពាក្យ Primary word | ថ្នាក់ Class | សេចក្តីពន្យល់ Explanation | យោង Reference |
|---|---|---|---|---|
| ៤៣ | ត្រល់ | ន | ប្រដាប់ធ្វើដោយពក "ឫស្សីពក" ឬឈើនាងនួនសម្រាប់ដាក់ខ្នារដែលខារអំបោះ | ជា ពិសី ១៩៩៤ |
| 43 | Troal | n. | This is made of pork (a kind of bamboo) or neangnuon ( a name of hight value tree) to support silk spools. | |
| ៤៤ | ត្រក | កិ | ជាសកម្មភាពមួយ ដែលធ្វើឲ្យសរសៃសូត្ររីកធំឡើង ដោយប្រើប្រាស់ពក ឬ ដាមគាស់ដើម្បីឲ្យងាយស្រួលដាក់កម្ពស់ត្រក | គង់ គន្ធារី ១៩៩៤ |
| 44 | Trork | v. | An action to make silk bigger by using pork or streaked wood or lifted streaked wood to make it easier to set the level of trork. | |
| ៤៥ | ត្រសូត្រ | កិ | ជាពាក្យមួយដែលគេបានជួបប្រទះនៅផ្ទះអ្នកត្បាញ ក្នុងខេត្តតាកែវ និងតំបន់ផ្សេងៗទៀតផ្នែកខាងត្បូងនៃប្រទេស | គង់ គន្ធារី ១៩៩៤ |
| 45 | Trosotr | v. | This means country. We see this word used in Takeo province and other parts of southern Cambodia. | |
| ៤៦ | ថ្ករ | កិ | ឆ្វាក់តង្ករត្បាញ | ជា ពិសី ១៩៩៤ |
| 46 | Thkor | v. | To tie silk for weaving. | |
| ៤៧ | ថ្ដេច | កិ | ផ្ទាត់តម្ដេចៈ ថ្ដេចកប្បាស | ជា ពិសី ១៩៩៤ |
| 47 | Card | v. | To make line or threads. | |

| លរ.<br>No | មេពាក្យ<br>Primary word | ថ្នាក់<br>Class | សេចក្តីពន្យល់<br>Explanation | យោង<br>Reference |
|---|---|---|---|---|
| ៤៨ | ទឹកក្បុង | ន | បានមកពីការកម្ទោចផ្ទី ឬគរជាដើម សម្រាប់យក ទឹកប្រៃលាងរបស់ផ្សេងៗ ឬលាយនឹងមរឲ្យក្លាយជាធ្លះ | ជា ពិសី<br>១៩៩៤ |
| 48 | Potash water | n. | This is made from ashes (Amaranthus spinosus L. Kapok ) to wash something or mix with mor to become dhlah. | |
| ៤៩ | ទឹកបាយ | ន | ទឹកពណ៌សខាប់អន្ទិល បានមកដោយសារ បាយ ឬ ម្សៅមី ដែលគេយកមកឲ្យបាយ សូត្រ ដើម្បីឲ្យការត្បាញរអិលបានស្រួល | គង់ គន្ធារី<br>១៩៩៤ |
| 49 | Toek bay | n. | Thick and white water from rice or casava powder, which softens silk for weaving. | |
| ៥០ | ធ្មេញកោស | ន | គឺជាប្រភេទធ្មេញឈើម៉្យាង ដែលធ្មេញ របស់វាធ្វើអំពីបន្ទះឫស្សីស្តើងៗ ហើយញឹក | គង់ គន្ធារី<br>១៩៩៤ |
| 50 | Scraped comb | n. | Thin and dense comb made of bamboo. | |
| ៥១ | ធ្មេញឈើ | ន | គឺជាឧបករណ៍ម៉្យាង ដែលមានរាងដូចជា ស្និតសិតថៃ សម្រាប់យកមកប្រើប្រាស់ក្នុង ការត្បាញ សម្រាប់ បញ្ចូលសរសៃអន្ទង់ នឹង កាសបញ្ចូលចាក់តម្បាញ | គង់ គន្ធារី<br>១៩៩៤ |
| 51 | Wooden comb | n. | A tool like our hair comb, used for weaving. | |

| លរ. No | មេពាក្យ Primary word | ថ្នាក់ Class | សេចក្តីពន្យល់ Explanation | យោង Reference |
|---|---|---|---|---|
| ៥២ | ធ្មេញស្រាវ | ន | ជាធ្មេញឈើម៉្យាង ដែលធ្មេញរបស់វាធ្វើអំពីបន្ទះឫស្សីក្រាស់ ហើយមិនសូវញឹក | គង់ គន្ធារី ១៩៩៤ |
| 52 | Slender comb | n. | Loose comb made of bamboo. | |
| ៥៣ | ធ្លះ | ន | ទឹកជ្រលក់មានពណ៌ខៀវធ្វើពីមរ លាយនឹងទឹកដាក់កំបោរស: សំពត់ជ្រលក់ធ្លះពណ៌ធ្លះ | គង់ គន្ធារី ១៩៩៤ |
| 53 | Dhlah | n. | Dyeing liquid (blue) was made of Mor and mixed with shell lime liquid. | |
| ៥៤ | ធ្លះប្រៃ | ន | គឺជាធ្លះម៉្យាង ដែលគេដាក់កំបោរ និងទឹកប៉ូតាសច្រើនលើសលប់ | គង់ គន្ធារី ១៩៩៤ |
| 54 | Salty Dhlah | n. | A kind of dhlah added with excessive lime and potash liquid. | |
| ៥៥ | ធ្លះសាប | ន | គឺជាធ្លះម៉្យាង ដែលគេដាក់កំបោរ និងទឹកប៉ូតាសមមិនគ្រប់គ្រាន់ | គង់ គន្ធារី ១៩៩៤ |
| 55 | Bland Dhlah | n. | A kind of dhlah that was not sufficiently added with lime and potash liquid. | |
| ៥៦ | នាឡិ | គុ | គឺជាខ្នាតទម្ងន់បុរាណ ដែលមានទម្ងន់ស្មើនឹង ៦៥០ ក្រាម | គង់ គន្ធារី ១៩៩៤ |
| 56 | Neal | adj. | A weight measurement equal 650 grams. | |
| ៥៧ | បោក | កិ | គឺជាសកម្មភាពម៉្យាង ក្នុងពេលជ្រលក់ពណ៌សូត្រ ដើម្បីឲ្យពណ៌ជាប់ទៅនឹងសរសៃសូត្របានល្អ | គង់ គន្ធារី ១៩៩៤ |
| 57 | Beat | v. | An action to make the silk thread absorb the color dyes. | |

| លរ No | មេពាក្យ Primary word | ថ្នាក់ Class | សេចក្តីពន្យល់ Explanation | យោង Reference |
|---|---|---|---|---|
| ៥៨ | បន្ទុំល័ខ | កិ | គឺគេទុកល័ខឲ្យនៅលើដើមឈើ រហូតដល់ល័ខបានទុំល្អ | គង់ គន្ធារី ១៩៩៤ |
| 58 | Bantum leak | v. | To keep red dye on trees until it is ripe, and ready to yield high quality dye. | |
| ៥៩ | ប្រមោកទឹកក្បុង | កិ | គឺជាសកម្មភាពលាងសរសៃសូត្រឆៅជាមួយនឹងទឹក ប៉ូតាស | គង់ គន្ធារី ១៩៩៤ |
| 59 | Beating with potash water | v. | An action to wash raw silk with potash water. | |
| ៦០ | ប្រែង | ន | ជាប្រភេទច្រាសពិសេសម៉្យាង ដែលគេប្រើប្រាស់វាសម្រាប់ឲ្យបាយសូត្រនៅពេលត្បាញ | គង់ គន្ធារី ១៩៩៤ |
| 60 | Braeng | n. | A special comb which is used to apply when weaving. | |
| ៦១ | ផាឌិប | ន | “ផាៈ សំពត់ ឌិបៈ ឆៅ” = សំពត់ឆៅដែលគេត្បាញ ដោយអំបោះឆៅឥតឲ្យបាយដូវទេ | ជា ពិសី ១៩៩៤ |
| 61 | Phadib | n. | Pha means cloth; dib means raw; [together] means raw cloth weaving without giving sour rice. | |
| ៦២ | ផុរ | កិ | ខ្ទុរ ខ្សុលចេញ រសោះចេញពីហុងៈ អំបោះផុរ | ជា ពិសី ១៩៩៤ |
| 62 | To be bubbling | v. | This refers to cotton or silk threads that have rolled out of spools. | |
| ៦៣ | ផាមួង | ន | ជាសំពត់សូត្រម៉្យាង (ដែលក្លាយមកពីពាក្យសៀមៈ ផាប្រែថាសំពត់ មួង ប្រែថា ពណ៌ស្វាយ) | គង់ គន្ធារី ១៩៩៤ |
| 63 | Phamuong | n. | A kind of cloth (derived from a Siam word, pha means cloth and muong means violet). | |

| លរ.<br>No | មេពាក្យ<br>Primary word | ថ្នាក់<br>Class | សេចក្ដីពន្យល់<br>Explanation | យោង<br>Reference |
|---|---|---|---|---|
| ៦៤ | ផ្លូលពណ៌ | កិ | គឺជាសកម្មភាពជ្រលក់ពណ៌សូត្រជាមួយនឹងព្រហូត មុននឹងគេជ្រលក់ពណ៌ផ្សេងៗទៀត | គង់ គន្ធារី ១៩៩៤ |
| 64 | To dye | v. | Action to dye silk with prahout color first before dyeing with other colors. | |
| ៦៥ | ផ្ដេកមក្លឿ | កិ | គឺគេជ្រលក់មក្លឿ | គង់ គន្ធារី ១៩៩៤ |
| 65 | To dye with makhloeur | v. | Dyeing with makhloeur (black color). | |
| ៦៦ | ផ្ទៃ | ន | គឺជាផ្នែកកណ្ដាលនៃសំពត់ ដែលមិនមែនជាជើង | គង់ គន្ធារី ១៩៩៤ |
| 66 | Surface | n. | The main part of cloth, not the hem. | |
| ៦៧ | ផ្សំ | ន | គឺជាឧបករណ៍មួយរបស់កី ធ្វើអំពីកំណាត់ឈើរាង ៤ ជ្រុង សម្រាប់មូរសំពត់នៅពេលត្បាញ | គង់ គន្ធារី ១៩៩៤ |
| 67 | Joining wood | n. | A spare part of the loom, which is made from quadrilateral-shape wood and used for rolling up cloth after it is woven. | |
| ៦៨ | ពក ឬ ដាមគាស់ | ន | ជាឧបករណ៍ម៉្យាងដែលធ្វើអំពីឬស្សី ឬឈើ សម្រាប់បំប៉ោងផ្ទៃសរសៃសូត្រនៅពេលថ្ករ ដែលគេបានចែករួចមកហើយ ដោយសារដាមរើស | គង់ គន្ធារី ១៩៩៤ |
| 68 | Pork or pry up streaking wood | n. | A tool made of wood or bamboo, used for swelling the silk surface when they had thkor by select streaking wood. | |

| លេខរៀង No | មេពាក្យ Primary word | ថ្នាក់ Class | សេចក្ដីពន្យល់ Explanation | យោង Reference |
|---|---|---|---|---|
| ៦៩ | ពិដាន | ន | ជាសំពត់ហូលម៉្យាងសម្រាប់ប្រើប្រាស់ក្នុងសាសនា ។ គេមិនដែលយកពិដានមកកាត់ជាសម្លៀកបំពាក់ទេ | គង់ គន្ធារី ១៩៩៤ |
| 69 | Pidan (Ceiling) | n. | A kind of hol used in religious ceremonies. We never dress this kind of cloth. | |
| ៧០ | ព័ន្ធមូល | ន | ឈើមួយគូសម្រាប់ដាក់ផ្ទួបក្ដាររមូរតម្បាញភ្ជាប់សរសៃអន្ទង | ជា ពិសី ១៩៩៤ |
| 70 | Round wood | n. | A pair of wood pieces placed next to rolling wood. | |
| ៧១ | ពាក់ដាម | កិ | ពាក់អំបោះនិងកូនអន្ទងដោយខ្វែងម្រាមដៃ | ជា ពិសី ១៩៩៤ |
| 71 | hang streaking wood | v. | To hang silk thread and kon antorng by crossing fingers. | |
| ៧២ | មរ (ម) | ន | ភក់ដែលកើតអំពីទឹកត្រាំដើមត្រុំ ព្រមទាំងស្លឹកត្រុំស្រស់ផង ឲ្យរលួយហើយកូរឲ្យខះកកមានសម្បុរខ្មៅ ខៀវទៅជាធ្លះសម្រាប់ប្រើជាគ្រឿងជ្រលក់ ។ | គង់ គន្ធារី ១៩៩៤ |
| 72 | Mor | n. | Mud resulingd from the soaked trom tree, which is kept until rotten and stirred until it is dark blue [and suitable] for dyeing. | |
| ៧៣ | ម្ជូរព្រៃ | គុ | គឺជាទឹកម្ជូរដែលបានមកអំពីដើមឈើ ស្លឹក និងផ្លែឈើ ដែលដុះនៅក្នុងព្រៃ | គង់ គន្ធារី ១៩៩៤ |
| 73 | Wild sour spice | adj. | This is made from a wild tree, leaves and fruits. | |

| លេ.រ<br>No | មេពាក្យ<br>Primary word | ថ្នាក់<br>Class | សេចក្តីពន្យល់<br>Explanation | យោង<br>Reference |
|---|---|---|---|---|
| ៧៤ | រងជើង | ន | គឺជាផ្នែកខាងក្នុងចុងជាយសំពត់ | គង់ គន្ធារី ១៩៩៤ |
| 74 | Rong choeung | n. | This is the end part of the hem. | |
| ៧៥ | រវៃគួបមុខសូត្រ | កិ | គឺជាបច្ចេកទេស យកសរសៃសូត្រច្រើនមកបង្រួមចូលគ្នា ឲ្យទៅជាមួយសរសៃធំល្មមអាចប្រើប្រាស់បាន | គង់ គន្ធារី ១៩៩៤ |
| 75 | Combining<br>silk hair thread | v. | A technique to bring many silk threads together as desired. | |
| ៧៦ | រវៃឲ្យខ្នាញ់ | ន | គឺជាបច្ចេទេសម៉្យាង ដែលគេធ្វើបន្ទាប់ពីការរវៃគួបមុខ ដើម្បីធ្វើឲ្យសរសៃសូត្រឡើងខ្នាញ់ល្អ | គង់ គន្ធារី ១៩៩៤ |
| 76 | To spin tightly | n. | A technique used after we have interwoven silk threads firmly. | |
| ៧៧ | រ៉ក | ន | ប្រដាប់មានភ្លៅ សណ្ឋានខូងជុំវិញ វិលបានធូរស្រួល សម្រាប់សិកខ្សែ ឬពួរទាញអ្វីៗយោងឡើង ឬសម្រូតចុះដោយងាយៈ រ៉កកន្ទុយហង្ស រ៉កផ្កាចាន់ ប្រើសម្រាប់ទាញតង្កើរឲ្យហើប | គង់ គន្ធារី ១៩៩៤ |
| 77 | Pulley | n. | A tool which has two poles with a hollow shape, and holes through which we can insert a line to pull things up and down easily. | |

| ល.រ<br>No | មេពាក្យ<br>Primary word | ថ្នាក់<br>Class | សេចក្ដីពន្យល់<br>Explanation | យោង<br>Reference |
|---|---|---|---|---|
| ៧៨ | រង្វើង | ន | ប្រដាប់មានស្នាបធ្វើដោយ ឬស្សីមានភ្លៅ មានដៃ សណ្ឋានដាវរហាត់ធំខ្ពស់ស្រោង មានជើងខ្ពស់សម្រាប់ ព័ទ្ធសូត្រ ឬអំបោះ ស្នាបរង្វើង ជើងរង្វើង | គង់ គន្ធារី ១៩៩៤ |
| 78 | Rongvoeung | n. | A tool made of bamboo in a wheel shape with long food and handles for linking the threads. | |
| ៧៩ | រើស | កិ | ស្រាល់ជ្រើស សម្រាំងយកតាមពេញចិត្ត ឬតាមត្រូវការ | គង់ គន្ធារី ១៩៩៤ |
| 79 | select | v. | To choose materials. | |
| ៨០ | រហាត់ | ន | ប្រដាប់សម្រាប់រវៃ ខារ ស្រូប វេញ មានច្រើនបែបៈ រហាត់រវៃ (សូត្រ) | គង់ គន្ធារី ១៩៩៤ |
| 80 | Rohat | n. | A kind of spinning device; a tool used for rolling up, spinning, twisting threads, etc. | |
| ៨១ | រម្ងាស់ | កិ | គឺដាំទឹកឲ្យពុះយ៉ាងយូរ នូវវត្ថុធាតុដើមឲ្យ ចេញជាពណ៌ ដែលគេត្រូវការ | គង់ គន្ធារី ១៩៩៤ |
| 81 | Decoct | v. | To cook dyeing materials for a long time to get colors. | |
| ៨២ | ល័ខ | ន | ក្នុងភាសាអ្នកត្បាញ ល័ខគេសម្គាល់វត្ថុធាតុ ទាំងឡាយណា អាចធ្វើឲ្យសូត្រមាន ពណ៌ផ្សេងៗ | គង់ គន្ធារី ១៩៩៤ |
| 82 | Leak (color) | n. | In weaving technique, leak means all materials that can color silk. | |

| លេខរៀង<br>No | មេពាក្យ<br>Primary word | ថ្នាក់<br>Class | សេចក្ដីពន្យល់<br>Explanation | យោង<br>Reference |
|---|---|---|---|---|
| ៨៣ | ល័ខជ្រុះ | ន | គឺនៅពេលដែលល័ខងាប់ ហើយកើតឡើងសារជាថ្មី ខ្ទួនវាយ៉ាងច្រើន | គង់ គន្ធារី ១៩៩៤ |
| 83 | Dropping leak | n. | This is said when insects that produce red dye die and re-birth in large quantity. | |
| ៨៤ | ល្បើក | ន | គឺជាសំពត់សូត្រខ្សែសយ ទឹកមាស ឬទឹកប្រាក់ មានកូន ផ្កាតូចៗ | គង់ គន្ធារី ១៩៩៤ |
| 84 | Lboeuk | n. | A kind of cloth made from golden or silver braid in the patterns of the small flowers. | |
| ៨៥ | ដើមសង្កែ | ន | គឺជាដើមឈើម្យ៉ាងដុះក្នុងព្រៃតូចៗ ដែលគេយកដើមរបស់វាទៅធ្វើជាអុសដុតផេះ សម្រាប់ផលិតទឹកក្បុង និងស្លឹករបស់វា សម្រាប់អ្នកស្រែមូរបារីជក់ | គង់ គន្ធារី ១៩៩៤ |
| 85 | Sangke tree | n. | A tree that growths in sparse forest, which can be used as firewood. Its ashes can produce potash water and some people use its leaves to roll cigarettes. | |
| ៨៦ | សារបាប់<br>(សារ៉ះ) | ន | (ក្ល. ជរបាប់) ឈ្មោះសំពត់មានសាច់ក្រាស់ធ្ងន់ ត្បាញដោយ សូត្រលាយខ្សែសយទឹកមាស ឬទឹកប្រាក់ដោយលើកជា គោមរំលេចដោយក្បាច់រចនា ជាសំពត់មានតម្លៃច្រើនៈ សំពត់សារបាប់(ហៅចរបាប់ ឬចារបាប់) | គង់ គន្ធារី ១៩៩៤ |
| 86 | Sarabab | n. | A kind of thick cloth made from silk and gold or silver braid. | |

| លេ.រ<br>No | មេពាក្យ<br>Primary word | ថ្នាក់<br>Class | សេចក្ដីពន្យល់<br>Explanation | យោង<br>Reference |
|---|---|---|---|---|
| ៨៧ | សូត្រក្បាល | ន | គឺសូត្រឆៅ គុណភាពអន់បំផុត បានមកអំពីដង្កូវនាងមានជម្ងឺ | គង់ គន្ធារី ១៩៩៤ |
| 87 | Head of silk | n. | This is raw and low-quality silk. Sick silkworms produce this kind of silk. | |
| ៨៨ | សូត្រដៃ | ន | គឺសូត្រឆៅដែលមានគុណភាពទាប | គង់ គន្ធារី ១៩៩៤ |
| 88 | hand silk | n. | This is raw and low-quality silk. | |
| ៨៩ | សូត្រសាច់ | ន | គឺជាសូត្រឆៅ ដែលមានគុណភាពល្អបំផុត | គង់ គន្ធារី ១៩៩៤ |
| 89 | Substantial silk | n. | The raw and high quality silk. | |
| ៩០ | សូត្រ ស | ន | គឺសូត្រឧស្សាហកម្មដែលមានពណ៌ស | គង់ គន្ធារី ១៩៩៤ |
| 90 | White silk | n. | This is industrialized silk which is white. | |
| ៩១ | សូត្រក្រហម | ន | គឺសូត្រឧស្សាហកម្មដែលមានពណ៌ក្រហម | គង់ គន្ធារី ១៩៩៤ |
| 91 | Red silk | n. | This is the red industrialized silk. | |
| ៩២ | ស្រពាប់ | គុ | គឺជាកម្រិតដែលគេហាលស្ងួតបន្ទរ | គង់ គន្ធារី ១៩៩៤ |
| 92 | Partially dry | adj. | This is the level of exposing things to sun and wind. | |
| ៩៣ | ហ៊ុនម្ខូរ | ន | ប្រដាប់សម្រាប់មួរអំបោះអន្ទង មានសណ្ឋានដូចនឹងហ៊ុនអំបោះតូចៗ “បែបសម័យ” | គង់ គន្ធារី ១៩៩៤ |
| 93 | Rolling spool | n. | A tool to roll silk or cotton thread that is similar to a small spool (modern). | |

| លេ.រ No | មេពាក្យ Primary word | ថ្នាក់ Class | សេចក្ដីពន្យល់ Explanation | យោង Reference |
|---|---|---|---|---|
| ៩៤ | ហូល | ន | គឺជាសំពត់សូត្រម៉្យាង ដែលរចនាដោយក្បាច់ផ្កា និងរូបធរណីមាត្រផ្សេងៗសម្រាប់ប្រើប្រាស់ធ្វើជាសម្លៀកបំពាក់ | គង់ គន្ធារី ១៩៩៤ |
| 94 | Hol | n. | A kind of silk cloth, which is decorated with flowers and other geometrical representations used for dressing. | |
| ៩៥ | ទ្បុត | ន | គឺជាខ្នារម៉្យាង ដែលមានខ្នាតខ្លីបំផុត | គង់ គន្ធារី ១៩៩៤ |
| 95 | Tube | n. | A kind of bobbinet spool which is very short. | |
| ៩៦ | អន្ទង | កិ | គឺជាបច្ចេកទេសមួយនៃការត្បាញ សម្រាប់រៀបចំសរសៃសូត្រ ក្រោយពេលដែលបានជ្រលក់ពណ៌រួចៗ នាំសរសៃអំបោះ ឬសូត្រទៅមកៗ រៀបចំអំបោះឲ្យមាន បណ្ដោយគ្នា ហើយមូរដោយក្ដារមូរ ដាក់ព័ន្ធមូលនឹងដាម ដើម្បីថ្កូរត្បាញៈ អន្ទងអំបោះ អន្ទងសូត្រ | គង់ គន្ធារី ១៩៩៤ |
| 96 | Weave | v. | A technique to prepare silk or cotton threads after they are dyed, bringing silk or cotton threads forward and back parallel and rolling them up around wood and streaking wood to thkor. | |

| ល.រ<br>No | មេពាក្យ<br>Primary word | ថ្នាក់<br>Class | សេចក្តីពន្យល់<br>Explanation | យោង<br>Reference |
|---|---|---|---|---|
| ៩៧ | អន្ទញ | ន | គឺជាសំពត់សូត្រម៉្យាងដែលមានឆ្នូតបណ្តោយពីលើចុះ ក្រោម ៗ កាលណាគេនិយាយថាសំពត់ហូលអន្ទញ មានន័យថា សំពត់ហូលនោះមានរូបឆ្លាស់គ្នា ជាមួយនឹងរូបឆ្នូតៗចុះក្រោម | គង់ គន្ធារី ១៩៩៤ |
| 97 | Checked cloth | n. | A kind of silk cloth that has stripes from top to bottom. When people say checked hol this means the pictures and stripes alternate on the cloth surface. | |
| ៩៨ | អ័ក្សអន្ទុង | កិ | គ្រឿងប្រដាប់របស់ខ្មែរ មួយប្រភេទធ្វើដោយឈើខ្លឹម មានកាំ មានរបាខ្នង មានសណ្ឋានមូល ខាងពោះមានសណ្ឋានសំប៉ែត រាយរង្អើលៗ ចុងទាំងពីរខាងបញ្ចុះ ភ្ជាប់ចុងកាំ មានក្ងៀវិលបាន មានជើងទ្រមាំ មានដៃសម្រាប់កាន់បង្វិល | គង់ គន្ធារី ១៩៩៤ |
| 98 | Spindle | v. | A kind of Khmer tool that is made from heartwood with rainks, round crossbar and flat bottom. At the end of each poles, there are rainks, supporter and a handle for turning it around. | |

| លេ.រ<br>No | មេពាក្យ<br>Primary word | ថ្នាក់<br>Class | សេចក្ដីពន្យល់<br>Explanation | យោង<br>Reference |
|---|---|---|---|---|
| ៩៩ | អំបោះ | ន | ១. ជាសរសៃសំឡីដែលរវៃរួចហើយ មាន-ប្រវែងវែង សម្រាប់ត្បាញក្រមា សំពត់ ជាដើម ជាអំបោះឆៅ<br>២.ជាសរសៃអំបោះផលិតចេញពីរោងចក្រមានពណ៌ គ្រប់ពណ៌ ហើយជាប់មាំនិងមានភាពរលោងជាងអំបោះ ដែលធ្វើដោយដៃ | គង់ គន្ធារី<br>១៩៩៤ |
| 99 | Cotton | n. | 1.The raw cotton thread that is already spun for weaving scarves, etc.<br>2.The threads in various colors, produced in factories, which is firm and smoother than hand-made cotton thread. | |
| ១០០ | ឲ្យបាយ | កិ | ឲ្យទឹកបាយ ឬបបរ ឬមេម្សៅម៉ដ្ឋលាយនិងទឹកឆៅ ដើម្បីឲ្យអំបោះឆៅក្លាយជាអំបោះឆ្អិន មានគុណភាពមាំជាប់បានយូរ | គង់ គន្ធារី<br>១៩៩៤ |
| 100 | Giving rice | v. | The process to make raw cotton threads or silk become mature and has good quality. | |


Laos
Thailand
Otday Mean Chey
Samrong
Banteay Mean Chey
Poipet
Sisophon
Siem Reap
Siem Reap (Angkor Tamples)
Choam Ksan
Preah Vihear
Stueng Treng
Stuang Trang
Rottana Kiri
Banlung
Mekong River
Battambang
Tonle Sap Lake
Pailin
Sambor Tamples
Kampong Thom
Kracheh
Mondol Kiri
Sen Monorom
Pursat
Tonle Sap
Kampong Chhnang
Kampong Cham
Koh Kong
Kampong Speu
Kompong Speu
Phnom Penh
Prey Veng
Svay Rieng
Nak Leong
Kandal
Gulf of Thailand
Vietnam
Takeo
Koh Thom
Kampot
Sihanoukville (Kampong Som)
Krong Preah Sihanouk
Kep
Krong Keb


KAMPONG SPEU
KANDAL
KOMPOT
KOMPOT
VIET NAM
TAKEO
Tonle Bati
Phnom Ta Mao
76km
Prasat
Neang Khmau
Phnom Chi Sou
Samraong
Pray Kabbas
Tramkak
Doun Kaev
Angkor Borei
Ponhea Lueu
Treang
Bourei Cholsar
Kaoh Andaet
53km
Kiri Vong
Phnom Bayang
Phnom


ខេត្តកំពង់ឆ្នាំង
ខេត្តកំពង់ចាម
ខេត្តកំពង់ស្ពឺ
ខេត្តព្រៃវែង
ខេត្តតាកែវ
ខេត្តព្រៃវែង
ប្រទេសវៀតណាម
Silver Smith
Mukh Kampul
31km
Phum Baset
Lvea Aem
Golf Course
Angk Snuol
KANDAL
Ta Khmau
Kandal Stung
S'ang
Angkor Chey
42km
Leuk Dek
Kaoh Thum


To Kampong Thom
KAMPONG THOM
KAMPONG CHHNANG
KRATIE
KAMPONG CHAM
KANDAL
PREYVENG
VIETNAM

# បញ្ជីឈ្មោះអ្នកដែលបានផ្តល់សម្ភាសន៍

## List of interviewed people

១. លោកតា **ជិន ឆែម** អាយុ ៦៥ ឆ្នាំ នៅភូមិបាទី ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ
*Ta Chin Chem, 65, Bati village, Kraing Dhnung commune, Bati district, Takeo province*

២. លោកយាយ **នូ សុខនា** អាយុ ៦៥ឆ្នាំ នៅភូមិបាទ ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ
*Yeay Nou Sok Nea, 65, Bati village, Kraing Dhnung commune, Bati district, Takeo province*

៣. អ្នកមីង **កូវ សាម៉េត** អាយុ ៥៤ ឆ្នាំ នៅភូមិរំចេក ឃុំត្នោត ស្រុកបាទី ខេត្តតាកែវ
*Ms. Kov Samet, 54, Rom Chek village, Thnot commune, Bati district, Takeo province*

៤. បងស្រី **ស៊ីណាត** អាយុ ៣៥ ឆ្នាំ នៅភូមិរំចេក ឃុំត្នោត ស្រុកបាទី ខេត្តតាកែវ
*Ms. Sinat, 35, Rom Chek village, Thnot commune, Bati district, Takeo province*

៥. លោក **ឆិល សាត** អាយុ ២៧ ឆ្នាំ នៅភូមិរំចេក ឃុំត្នោត ស្រុកបាទី ខេត្តតាកែវ
*Mr. Chil Sat, 27, Rom Chek village, Thnot commune, Bati district, Takeo province*

៦. អ្នកស្រី **ស្រីមុំ** នៅភូមិរំចេក ឃុំត្នោត ស្រុកបាទី ខេត្តតាកែវ
*Ms. Mom, Rom Chek village, Thnot commune, Bati district, Takeo province*

៧. អ្នកមីង **ហេង សំ** អាយុ ៥០ ឆ្នាំ ភូមិរំចេក ឃុំត្នោត ស្រុកបាទី ខេត្តតាកែវ
*Ms. Heng Sam, 50, Rom Chek village, Thnot commune, Bati district, Takeo province*

៨. **ឌុច ស៊ីណាន** អាយុ ២៥ ឆ្នាំ ភូមិរំចេក ឃុំត្នោត ស្រុកបាទី ខេត្តតាកែវ
*Ms. Duch Sinan, 25, Rom Chek village, Thnot commune, Bati district, Takeo province*

៩. អ្នកស្រី **ឌុច ចន្ថា** អាយុ ២១ ឆ្នាំ ភូមិរំចេក ឃុំត្នោត ស្រុកបាទី ខេត្តតាកែវ
*Ms. Duch Chantha, 21, Rom Chek village, Thnot commune, Bati district, Takeo province*

១០. អ្នកស្រី **តុង សៀវអេង** អាយុ ៤២ ឆ្នាំភូមិទំនប់ ឃុំត្នោត ស្រុកបាទី ខេត្តតាកែវ
*Ms. Tong Siev Eng, 41, Tumnob village, Thnot commune, Bati district, Takeo province*

១១. អ្នកស្រី **សំរិត ឡាង** អាយុ ៤២ ឆ្នាំ ភូមិទំនប់ ឃុំត្នោត ស្រុកបាទី ខេត្តតាកែវ
*Ms. Samrit Lang, 42, Tumnob village, Thnot commune, Bati district, Takeo province*

១២. លោកយាយ **ណាង** អាយុ ៦៥ ឆ្នាំ ភូមិទំនប់ ឃុំត្នោត ស្រុកបាទី ខេត្តតាកែវ

*Yeay Neang, 65, Tumnob village, Thnot commune, Bati district, Takeo province*

១៣. អ្នកស្រី **សំ សុគាំ** អាយុ ៥០ ឆ្នាំ នៅភូមិពៃ ឃុំត្នោត ស្រុកបាទី ខេត្តតាកែវ

*Ms. Sam Sukorm, 50, Pei village, Thnot commune, Bati district, Takeo province*

១៤. លោក **សួង មិញ** អាយុ ៣៤ ឆ្នាំ នៅភូមិឈើទាល ឃុំត្នោត ស្រុកបាទី ខេត្តតាកែវ ជាគ្រូខាងសិប្បកម្មតម្បាញ នៅអង្គការ CYK និងមានបទពិសោធន៍ជាច្រើនផ្នែកតម្បាញជាពិសេស ផ្នែកពិដាន

*Mr. Suong Mich, 34, Chheu Teal village, Thnot commune, Bati district, Takeo province. He is a teacher of silk weaving at CYK association and he specializes in Piden weaving.*

១៥. លោក **ង៉ែត ម៉េង** អាយុ ៥៤ ជាថៅកែផ្ញើហូល ផាមួង សារុងសូត្រ នៅភូមិវាល ឃុំក្តាញ់ ស្រុកបាទី ខេត្តតាកែវ ។ លោកជាអាជីវករផង និងសិប្បករផង ហើយស្នាដៃរបស់គាត់ត្រូវបានទទួលស្គាល់យ៉ាងទូលាយក្នុងចំណោមអ្នកប្រើប្រាស់ ។ ស្នាដៃទាំងនោះមានដាក់លក់ជាច្រើនតូបក្នុងផ្សារធំថ្មី ជាពិសេសតូបលេខ ២២៥-២៤៦-២៤៨

*Mr. Nget Meng, 54, Veal village, Kdanh commune, Bati district, Takeo province. He is the whole seller and weaver of Hol, Phamuong and Sarong Sotr. His works are recognized in country and can be bought at Central Market especially houses №245,246,248.*

១៦. លោកយាយ **ស្រេង ស្រ៊ុន** អាយុ ៧៥ ឆ្នាំ នៅភុមិទំបន់ ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ

*Yeay Sreng Srun, 75, Tumnob village, Chambak commune, Bati district, Takeo province*

១៧. អ្នកស្រី **សុខុម** អាយុ ៤៩ ឆ្នាំ នៅភូមិទំនប់ ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ

*Ms. Sokhom, 49, Tumnob village, Chambak commune, Bati district, Takeo province*

១៨. លោកតា **ឈា ឈន** អាយុ ៨០ ឆ្នាំ ភូមិត្រពាំងចំបក់ (ហៅកុកដេក) ឃុំជីរះពេន ស្រុកសំរោង ខេត្តតាកែវ

*Ta Chea Chorn, 80, Trapeang Chambak ( called Kok Dek), Samreahpen commune, Samrong district, Takeo province*

១៩. លោកតា **អ៊ីម** អាយុ ៧៣ ឆ្នាំភូមិកន្សោមអក ឃុំសំរោង ស្រុកសំរោង ខេត្តតាកែវ គាត់ជាអ្នកធ្វើធ្មេញឫស្សីដែលមានបទពិសោធន៍ជាច្រើនឆ្នាំកន្លងមកហើយ តាំងពីមុនសម័យ ប៉ុល ពត មកទៀត

*Ta Im, 73, Kansom Ork village, Samrong commune, Samrong district, Takeo province*
*He produces bamboo comb since before Pol Pot's regime*

២០. លោកតា **ប៉ូ** អាយុ ៨១ ឆ្នាំ នៅភូមិព្រែកចង្ក្រានលើ ឃុំព្រែកចង្ក្រាន ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង

*Ta Po, 81, Prek Changkran Loeu village, Prek Changkran commune,*
*Sithor kandal district, Prey Veng province*

២១. លោកយាយ **គង់** អាយុ ៧៦ ឆ្នាំ នៅភូមិព្រែកចង្ក្រានលើ ឃុំព្រែកចង្ក្រាន ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង

*Yeay Kong, 76, Prek Changkran Loeu village, Prek Changkran commune,*
*Sithor kandal district, Prey Veng province*

២២. មីង **ទី** អាយុ ៥២ ឆ្នាំ នៅភូមិព្រែកចង្ក្រានលើ ឃុំព្រែកចង្ក្រាន ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង

*Ms. Ty, 52, Prek Changkran Loeu village, Prek Changkran commune,*
*Sithor kandal district, Prey Veng province*

២៣. លោកយាយ **ឡាង** អាយុ ៧៨ ឆ្នាំ នៅភូមិព្រែកចង្ក្រានលើ ឃុំព្រែកចង្ក្រាន ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង

*Yeay Lang, 78, Prek Changkran Loeu village, Prek Changkran commune,*
*Sithor kandal district, Prey Veng province*

២៤. លោកយាយ **ទី ណៃស្រ៊ីម** អាយុ ៦៧ ឆ្នាំ នៅភូមិព្រែកចង្ក្រានលើ ឃុំព្រែកចង្ក្រាន ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង

*Yeay Ty Naysrim, 67, Prek Changkran Loeu village, Prek Changkran commune,*
*Sithor kandal district, Prey Veng province*

២៥. លោក **ឡុង តុងហាន** អាយុ ៥៨ ឆ្នាំ នៅភូមិព្រែកចង្ក្រានលើ ឃុំព្រែកចង្ក្រាន ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ។ លោកជាសិប្បករផង និងអាជីវករផង

*Mr. Long Tong Han, 58, Prek Changkran Loeu village, Prek Changkran commune, Sithor kandal district, Prey Veng province. He is a weaver and seller.*

២៦. មីង **សុខ ខឿន** អាយុ ៥២ ឆ្នាំ នៅភូមិកោងទន្លេ ឃុំល្វេ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង

*Ms. Sok Khoeurn, 52, Kong Tonle village, Lve commune, Sithor kandal district, Prey Veng province*

២៨. លោកគ្រូ **បុត្រ** អាយុ ៣៧ ឆ្នាំ នៅផ្សារព្រែកសណ្តែក ឃុំព្រែកចង្ក្រាន ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ។ សព្វថ្ងៃលោកជាមនុស្សតែម្នាក់គត់នៅឃុំព្រែកចង្ក្រានដែលនៅជ្រលក់ពណ៌ដោយប្រើល័ក្តខ្មែរ

*Mr. Bot, 37, he lives at Prek Sandek market, Prek Changkran commune, Sithor kandal district, Prey Veng province. He is only weaver now inhis area to dye the silk using traditional colors*

២៩. បងស្រី **ផល្លី** អាយុ ៣៥ ឆ្នាំ នៅភូមិកោងទន្លេ ឃុំល្វេ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង

*Ms. Phally, 35, Kong Tonle village, Lve commune, Sithor kandal district, Prey Veng province*

៣០. លោកយាយ **ផាន** អាយុ ៦០ ឆ្នាំ នៅភូមិកោងទន្លេ ឃុំល្វេ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ជាអ្នកថ្ករសូត្រ

*Yeay Phan, 60, Kong Tonle village, Lve commune, Sithor kandal district, Prey Veng province*

៣១. ពូ **សេត ស្រន់** អាយុ ៥៣ ឆ្នាំ នៅភូមិចុងកោះ ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល

*Mr. Set Sroan, 53, Chong Koh village, Koh Dach commune, Mukh Kampoul district, Kandal province*

៣២. មីង **សំអាង** អាយុ ៥៤ ឆ្នាំ ភូមិក្បាលកោះ ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល និង ប្រជាជនមួយចំនួនទៀតដែលជាសិប្បករតម្បាញ

*Ms. Som Ang, 54, Kbal Koh village, Koh Dach commune, Mukh Kampoul district, Kandal province and other weavers.*

# បញ្ជីឯកសារយោង

# References


- ក្រមផងឯកសារស្តីពី ប្រពៃណី និងទំនៀមទម្លាប់ខ្មែរ ពុទ្ធសាសនបណ្ឌិត្យ ១៩៩៩

  (Dictionary of Plants used in Cambodia, Prof. Dy Phon Pauline, 2000)
- វិធីធ្វើហូលរបស់ស្ត្រីខ្មែរ ដោយលោក លី សុវីរ, ភ្នំពេញ ១៩៩៨

  (Documentations on Khmer Tradition, The Buddhist Institute, 1999)
- សៀវភៅសិក្សាស្តីអំពីខ្មែរ ក្បាច់ហូល ផាមួង សូត្រ បូរាណខ្មែរដោយសម្ព័ន្ធ សិប្បកម្ម កម្ពុជា និង អ្នកស្រី ប្រាង្គ សុន,ភ្នំពេញ

  (Method to produce Hol of Khmer women, Ly Sovy, Phnom Penh 1998)
- តម្បាញក្រមាខ្មែរ ដោយក. ជា ពិសី,ភ្នំពេញ ១៩៩៤

  (Book on Lantern study of old khmer Hol, Phamuong, Silk by Cambodia Craft Corporation and Ms. Prang Sun, Phnom Penh)
- តម្បាញផាមួងនៅកោះដាច់ ដោយក. គង់ គន្ធារី.ភ្នំពេញ ១៩៩៤

  (Khmer Scarf Weaving by Miss. Chea Pisey, Phnom Penh 1994)
- វចនានុក្រមខ្មែរ ភាគ១-២, ពុទ្ធសាសនបណ្ឌិត្យ ១៩៦៨ គ្រាបោះពុម្ពលើកទី៥

  (Khmer Dictionary part I-II, The Buddhist Institute, 1968, fifth edition)

រោងពុម្ពវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

The Buddhist Institute Printing House







KH/CLT/2007/BK/19
Phnom Penh, October 2008
Original: Khmer/English

ISBN-9789995050023